**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| **ឯកសារបកប្រែ** | |
| **TRANSLATION/TRADUCTION** | |
| ថ្ងៃ ខែ ឆ្នាំ (Date): | 27-Jul-2011, 15:26 |
| CMS/CFO: | Uch Arun |

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ គឺជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ ("សំណើសុំ")[១]។ អង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើសុំរបស់សហព្រះរាជអាជ្ញានេះ ដោយហេតុថាសំណើនេះជាអញ្ញត្រកម្មយឺតយ៉ាវមួយ ដែលជំទាស់ទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះជំទាស់នឹងការយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មកអនុវត្តនៅ អ.វ.ត.ក។ ម្យ៉ាងទៀត សំណើសុំនេះក៏គួរត្រូវបានបដិសេធដោយសារខ្វះសំអាងហេតុ។ សំអាងហេតុទាំងអស់ដែលមានក្នុងសំណើរបស់ ក.ស.ព នេះធ្លាប់ត្រូវបាន ក.ស.ព លើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះម្តងរួចមកហើយ[២]។ សំណើនេះពុំបានចង្អុលបង្ហាញថាសាលដីការបស់អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំជាក់ស្តែងណាមួយ ដែលធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសាលដីកានោះឡើយ។ កន្លងមកសាលដីការបស់អង្គបុរេជំនុំជម្រះបានសម្រេចថាតុលាការពុំអាចយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មកអនុវត្តនៅ អ.វ.ត.ក បានឡើយ។ ។ នៅក្នុងចម្លើយតបនេះ មេធាវីការពារក្តីសូមដាក់បញ្ចូលសារណាទាំងអស់ ដែលមាននាពេលកន្លងមកពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម[៣]។ ក្នុងការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការផ្ទាល់មាត់ជាសាធារណៈ។

## I. ចម្លើយតបលើបញ្ហានីតិវិធី៖ សំណើរបស់សហព្រះរាជអាជ្ញាជាសំណើយឺតយ៉ាវហើយអង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើនេះ

---

[១] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត, ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, លេខឯកសារ E 100។

[២] *សូមមើល* ឧបសម្ព័ន្ធ ១ ដែលមានតារាងរៀបរាប់អំពីទឡ្ហីករណ៍របស់ ក.ស.ព ដោយបង្ហាញអំពីបញ្ហានីមួយៗដែលត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

[៣] *សូមមើល* ឧបសម្ព័ន្ធ ២ ដែលរៀបរាប់អំពីឯកសាររបស់មេធាវីការពារក្តីដែលបានដាក់នាពេលកន្លងមក ស្តីពីបញ្ហាលទ្ធភាពក្នុងការយកសហឧក្រិដ្ឋកម្មរួមមកអនុវត្តនៅ អ.វ.ត.ក។

១. នៅពេលបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងបានទទួលការស្នើសុំឲ្យបដិសេធសាលដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការក្នុងការយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មកអនុវត្តនៅ អ.វ.ត.ក[4]។ នេះជាអញ្ញត្រកម្មមួយពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក។ នៅក្នុងការចង់ឲ្យមានការកំណត់បទចោទឡើងវិញទៅតាមអង្គហេតុ ក.ស.ព កំពុងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់អំពីប្រភេទនៃទម្រង់នៃការទទួលខុសត្រូវដែលមានជាធរមាន ហើយដែលអាចធ្វើទៅបានលុះត្រាតែអង្គជំនុំជម្រះសាលាដំបូងបដិសេធសាលដីការបស់អង្គបុរេជំនុំជម្រះជាមុនសិន។ អង្គបុរេជំនុំជម្រះបានសម្រេចថា អ.វ.ត.ក ពុំអាចយកគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣មកអនុវត្តបានឡើយ ដោយហេតុថាគោលការណ៍នេះគ្មានចែងក្នុងច្បាប់កម្ពុជា ឬក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ឡើយ។

២. ក្នុងសំណុំរឿង ០០២ ក.ស.ច.ស បានចេញដីកាសម្រេចមួយដែលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើទម្រង់ទាំង៣នៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមនេះ[5]។ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (“វិធាន”) មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចខាងលើរបស់ ក.ស.ច.ស “ដែលបញ្ជាក់ថា អ.វ.ត.ក មានយុត្តាធិការលើទម្រង់ទាំង៣នៃសហឧក្រិដ្ឋកម្មរួម”។ ដោយបានបញ្ជាក់ថាបណ្តឹងឧទ្ធរណ៍នេះធ្វើឡើងផ្អែកលើវិធាន ៧៤(៣)(ក) អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា អ.វ.ត.ក ពុំអាចយកគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មកអនុវត្តបានឡើយ ដោយហេតុថាគោលការណ៍

---

4 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE), ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, លេខឯកសារ D97/14/15 (“សាលដីការបស់ អ.ប.ជ លើ JCE”), កថាខណ្ឌ ៥១-៨៨។

5 ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩, លេខឯកសារ D97/13។

នេះពុំមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះ ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយជនជាប់ចោទក៏ពុំបានដឹងថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នេះជាបទល្មើសដែរ[៦]។

៣. ក្នុងការពិចារណាថាតើការអនុវត្តសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក គឺជាបញ្ហាយុត្តាធិការ អង្គបុរេជំនុំជម្រះបានសម្រេចថា អ.វ.ត.ក មានតួនាទីស្រដៀងនឹងតុលាការ *មិនអចិន្ត្រៃយ៍* ដែរ ត្រង់ថា "បញ្ហាស្តីពីអត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវ ឬបញ្ហាថាតើច្បាប់ទំនៀមទម្លាប់បានទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវនោះដែរឬទេ ក្នុងពេលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការ"[៧]។ វិធានផ្ទៃក្នុងដែលត្រូវបានអនុម័តជាពិសេស សម្រាប់ អ.វ.ត.ក បានចែងអំពីបញ្ហាយុត្តាធិការ[៨] ហើយវិធានផ្ទៃក្នុងមាន

---

[6] សាលដីការបស់ អ.ប.ជ លើ JCE, កថាខណ្ឌ ៧៥-៨៨។

[៧] ដូចដើងទំព័រខាងលើ, កថាខណ្ឌ ២៣-២៤។ ក្នុងសំណុំរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milutinovic* នៅតុលាការ ICTY, អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថាសារណារបស់ Ojdanic ពាក់ព័ន្ធនឹងបញ្ហាថាតើសហឧក្រិដ្ឋកម្មរួមស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ICTY គឺជាបញ្ហាយុត្តាធិការ។ សំណុំរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milutinovic*, លេខសំណុំរឿង IT-99-37-AR72, សាលដីកាលើបណ្តឹងរបស់ Dragoljub Ojdanic ជំទាស់ទៅនឹងយុត្តាធិការ-*សហឧក្រិដ្ឋកម្មរួម*, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣។ ក្នុងសំណុំរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadzic*, អង្គជំនុំជម្រះ សាលាដំបូងបានយល់ឃើញថាសារណារបស់ Karadzic ពាក់ព័ន្ធនឹងការលើកឡើងអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពាក់ព័ន្ធនឹងបញ្ហាថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ អាចយកមកអនុវត្តចំពោះបទល្មើសធ្ងន់ធ្ងរដែរ ឬយ៉ាងណានោះ ពុំមែនជាបញ្ហាយុត្តាធិការឡើយ។ ប៉ុន្តែ ពុំមានការតវ៉ាទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ឡើយ។ សំណុំរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadzic*, លេខសំណុំរឿង IT-95-5/18-PT, *សាលដីកាលើអញ្ញត្រកម្មចំនួន ៦ ជំទាស់ទៅនឹងយុត្តាធិការ*, ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

[៨] វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មដើម្បីបំព្រួញរយៈពេលនៃការលើកអញ្ញត្រកម្ម។ បញ្ហាអស់ទាំងនេះត្រូវដោះស្រាយឲ្យបានរួចរាល់នៅមុនពេលសវនាការ។ ត្រង់ចំណុចនេះ អ.វ.ត.ក ស្រដៀងទៅនឹងតុលាការ *មិនអចិន្ត្រៃយ៍* ដែលតម្រូវឲ្យមានការលើកឡើងនូវបញ្ហាយុត្តាធិការនានា ដូចជា យុត្តាធិការរបស់តុលាការលើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវមួយចំនួន ក្នុងរយៈពេលកំណត់ណាមួយនៅមុនពេលសវនាការចាប់ផ្តើម។ *សូមមើល* វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY, វិធាន ៧២ (ក), វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTR, វិធាន ៧២(ក)។

អាទិភាពលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[៩]។ វិធាន ៨៩(១) ចែងថាអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង "ត្រូវលើកឡើងយ៉ាងយូរ ៣០ ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ"។ ដោយហេតុថាដីកាដំណោះស្រាយបានចូលជាស្ថាពរតាំងពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ ដូច្នេះពេលវេលាកំណត់នៃការដាក់សេចក្តីជំទាស់ទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មទម្រង់ទី៣ គឺនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[១០]។

៤. ក.ស.ព ពុំបានដាក់អញ្ញត្រកម្មដោយអនុលោមតាមវិធាន ៨៩ ឡើយ។ *នៅពេលនេះ* ខ្លួនបែរជាអះអាងថាខ្លួនពុំចាំបាច់ធ្វើដូច្នោះទេ ពីព្រោះខ្លួនពុំជំទាស់ទៅនឹងយុត្តាធិការ អ.វ.ត.ក ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អ.វ.ត.ក[១១]។ នេះគឺជាអំណះអំណាងមិនពេញលេញ។ ទោះបីកិច្ចព្រមព្រៀង និងច្បាប់បង្កើត អ.វ.ត.ក ជាអ្នកផ្តល់យុត្តាធិការឲ្យ អ.វ.ត.ក ក្តី ក៏យុត្តាធិការ អ.វ.ត.ក នេះស្ថិតក្នុងក្របខ័ណ្ឌមួយដែលកំណត់ដោយដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយពុំបានលើកឡើងអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ឡើយ អនុ-លោមតាមសាលដីការបស់អង្គបុរេជំនុំជម្រះ[១២]។ *នៅពេលនេះ* ក.ស.ព បែរជាជំទាស់ទៅនឹង

---

[៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨, លេខឯកសារ D55/I/8, កថាខណ្ឌ ១៤។

[១០] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, លេខឯកសារ E9។

[១១] សំណើសុំ, ជើងទំព័រលេខ ១២។ អំណះអំណាងរបស់ ក.ស.ព ដែលថាការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មានជាធរមាន គឺស្ថិតនៅលើការបកស្រាយមាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ដូចដែលយើងបានឃើញពីទឡ្ហីករណ៍ទីមួយនៅក្នុងសំណើនេះ។ ចំណុចត្រង់នេះបញ្ជាក់អំពីគោលបំណងពិតប្រាកដនៃសំណើរបស់ ក.ស.ព នោះគឺជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។

[១២] *សូមមើល* ដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, លេខឯកសារ D427, ផ្នែកទី ២, I (ក្រោមចំណងជើង៖ សមត្ថកិច្ចយុត្តាធិការ អ.វ.ត.ក)។ អង្គបុរេជំនុំជម្រះចាត់ទុកលទ្ធភាពក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួម ជាបញ្ហាក្រោមវិធាន ៨៩ ពុំមែនវិធាន ៩៨ ទេ។ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ខ្លួនបានគូសបានបញ្ជាក់ថា៖ "អង្គបុរេជំនុំជម្រះទទួលស្គាល់

ការកំណត់ក្របខ័ណ្ឌយុត្តាធិការនេះទៅវិញ នៅពេលដែលពេលផុតកំណត់សម្រាប់អញ្ញត្រកម្ម ដោយអនុលោមតាមវិធាន ៨៩ បានកន្លងផុតទៅជិតប្អូនខែទៅហើយ។ ការដែល ក.ស.ព មិន បានដាក់អញ្ញត្រកម្មអាចជាយុទ្ធវិធីមួយ ឬដោយសារខ្វះការយកចិត្តទុកដាក់ត្រឹមត្រូវ។ ប៉ុន្តែ *នៅពេលនេះ* ក.ស.ព បែរជាស្នើសុំឲ្យ "អង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ថាជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលមានសុពលភាពគតិយុត្តនៅ អ.វ.ត.ក"[១៣] ទៅវិញ ក្នុងប្រភេទជាសំណើសុំ "កំណត់បទចោទឡើងវិញ" ដោយអនុលោម តាមវិធាន ៩៨ ដូចធ្លាប់បានអនុវត្តនាពេលកន្លងមកនៅក្នុងសំណុំរឿង ០០១[១៤]។ ដោយហេតុ ថាការកំណត់បទចោទឡើងវិញដោយអនុលោមតាមវិធាន ៩៨ ពុំមែនជាមធ្យោបាយមួយ ដើម្បីរំលងវិធាន៨៩ ដូច្នេះហើយការអនុវត្តវិធាន៩៨ក្នុងសំណុំរឿង ០០១ ពុំមានការចាំបាច់ ឡើយ។ ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថាសំណុំរឿង ០០១ និង ០០២ ពុំដូចគ្នាទេ។

៥. ស្ថានភាពនាពេលបច្ចុប្បន្នខុសគ្នាទាំងស្រុងពីស្ថានភាពនៅក្នុងសំណុំរឿង ០០១។ ក្នុងសំណុំ រឿង ០០១ ឌុច ពុំដែលបានតវ៉ាថាតើសហឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់ដែរ ឬអត់នោះ ទេ។ សហឧក្រិដ្ឋកម្មរួមត្រូវបាន ក.ស.ច.ស លុបចេញពីដីកាដំណោះស្រាយ។ អង្គបុរេជំនុំ ជម្រះបានសម្រេចថាខ្លួនពុំអាចដាក់បន្ថែមសហឧក្រិដ្ឋកម្មរួមទៅលើឌុចបានទេ ដោយហេតុថា ក្នុងអំឡុងកិច្ចស៊ើបសួរ ឌុច ពុំបានដឹងគ្រប់គ្រាន់ថាតុលាការអាចយកការទទួលខុសត្រូវនេះមក អនុវត្ត។ ក្នុងសំណុំរឿង ០០១ បញ្ហាថាតើគោលការណ៍សហឧក្រិដ្ឋកម្មរួម ពិតជាបានមាន ចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ឬយ៉ាងណានោះ <u>ពុំធ្លាប់បាន</u>អង្គបុរេជំនុំជម្រះ<u>លើក</u>

---

ថាវិធាន ៧៤(៣)(ក) និងវិធាន ៨៩(១) បើកចំហរនូវលទ្ធភាពនៃការលើកឡើងអំពីបញ្ហាយុត្តាធិការចំពោះមុខអង្គបុរេជំនុំ ជម្រះ និងអង្គជំនុំជម្រះសាលាដំបូង", សាលដីការបស់ អ.ប.ជ លើ JCE កថាខណ្ឌ ៣៥។

[១៣] សំណើសុំ, កថាខណ្ឌ ៤១។

[១៤] ដូចជើងទំព័រខាងលើ, កថាខណ្ឌ ៨។

<u>យកមកពិចារណា</u> ឡើយ[១៥]។ នៅក្នុងសវនាការ ក.ស.ព បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តគោលការណ៍ស្តីពីការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២ ឬទម្រង់ទី៣ ដោយផ្អែកលើការកំណត់បទចោទឡើងវិញទៅតាមអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ ដោយអនុលោមតាមវិធាន ៩៨[១៦]។ មេធាវីការពារក្តី ឌុច បានជំទាស់ទៅនឹងសំណើនេះ ប៉ុន្តែ <u>ពុំបានតវ៉ាទៅនឹងការយកសហឧក្រិដ្ឋកម្មរួមមកអនុវត្តនៅ អ.វ.ត.ក ឡើយ</u> ពោលគឺខ្លួនគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថាតើគោលការណ៍នេះអាចយកមកអនុវត្តនៅ អ.វ.ត.ក បានដែរ ឬទេ"[១៧]។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ.វ.ត.ក អាចយកគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២ មកអនុវត្តដោយពុំមានការប៉ះពាល់ណាមួយដល់សិទ្ធិរបស់ ឌុច ឡើយ ដោយហេតុថា ឌុច បានទទួលការជូនដំណឹង និងត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតបទៅលើបញ្ហានេះរួចហើយ[១៨]។ ដូច្នេះកាលពីក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានទទួលការស្នើសុំឱ្យសម្រេច

---

[១៥] *សំណុំរឿង កាំង ហ្កេកអ៊ាវ,* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨, លេខឯកសារ D99/3/42, កថាខណ្ឌ ១៤១-១៤២។

[១៦] *សំណុំរឿង កាំង ហ្កេកអ៊ាវ* , សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៩, លេខឯកសារ E73។

[១៧] ឌុច បានជំទាស់ថា៖ **ក.** សំណើរបស់ ក.ស.ព មានលក្ខណៈមិនអាចទទួលយកបាន អាស្រ័យដោយសាលដីការបស់អង្គបុរេជំនុំជម្រះសម្រេចលុបសហឧក្រិដ្ឋកម្មរួម ចេញពីដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្មថ្មី **ខ.** សំណើនេះគួរត្រូវបានបដិសេធដោយសារពុំមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់នៅក្នុងដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្មថ្មី សម្រាប់ធ្វើជាសំអាងហេតុចំពោះសហឧក្រិដ្ឋកម្មរួម និង **គ.** សហឧក្រិដ្ឋកម្មរួមពុំត្រូវបាន ក.ស.ព លើកឡើងឱ្យបានលម្អិតគ្រប់គ្រាន់ឡើយ។ *សំណុំរឿង កាំង ហ្កេកអ៊ាវ* , សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើឱ្យមានការអនុវត្តទៅលើរឿងក្តីនូវទ្រឹស្តី សហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩, លេខឯកសារ E73/2។

[១៨] *សំណុំរឿង កាំង ហ្កេកអ៊ាវ* , សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, លេខឯកសារ E188 ("សាលក្រមលើសំណុំរឿង ឌុច"), កថាខណ្ឌ ៥០១-៥០៣។

ថាតើខ្លួនគួរពិចារណាទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២ នៅក្នុងសាលក្រមដែរឬទេ ដោយផ្អែកលើអង្គហេតុនៃសំណុំរឿង[១៩]។

៦. លោក អៀង សារី ខុសពី ឌុច ត្រង់ថាលោក អៀង សារី បានតវ៉ាថាគោលការណ៍សហឧក្រិដ្ឋកម្មរួមគ្មានចែងក្នុងច្បាប់ទេ ហើយ អ.វ.ត.ក មិនអាចយកគោលការណ៍នេះមកអនុវត្តបានឡើយ។ មេធាវីការពារក្តីរបស់លោក អៀង សារី បានលើកបញ្ហានេះទាន់ពេលពេលវេលា និងមានការជជែកគ្នាយ៉ាងច្រើននៅមុនដំណាក់កាលជំនុំជម្រះ[២០]។ អនុលោមតាមវិធាន ៧៤(៣)(ក) អង្គបុរេជំនុំជម្រះជាអ្នកសម្រេចលើបញ្ហាយុត្តាធិការ។ ត្រង់នេះ ក.ស.ព ពុំបានជំទាស់ឡើយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើនេះ។

## II. ចម្លើយតបទៅលើខ្លឹមសារ៖ គោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពុំមែនជាគោលការណ៍ជាធរមាននៅ អ.វ.ត.ក ឡើយ

៧. សាលដីការបស់អង្គបុរេជំនុំជម្រះដែលបានសម្រេចថា អ.វ.ត.ក ពុំអាចយកគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មកអនុវត្តបាន ដោយហេតុថាគោលការណ៍នេះពុំមានចែងក្នុងច្បាប់ជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយជនជាប់

---

[១៩] ទោះបីសំណើរបស់ ក.ស.ព សុំដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមចូលទៅក្នុងសំណុំរឿង ០០១ ត្រូវបានចាត់ទុកថាជាបញ្ហាយុត្តាធិការក្តី ក៏អង្គជំនុំជម្រះអាចទទួលយកសំណើនោះ ដោយសារតែនៅពេលនោះវិធានផ្ទៃក្នុងតម្រូវឲ្យភាគីលើកបញ្ហាអញ្ញត្រកម្មនៅក្នុងសវនាការបឋម។ *សូមមើល* វិធានផ្ទៃក្នុង កែសម្រួលលើកទី ៣, វិធាន ៨៩។ នៅឯសវនាការបឋម ក.ស.ព ពិតជាបាន ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគី អំពីចេតនារបស់ខ្លួនក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរនៅពេលក្រោយ ដើម្បីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តគោលការណ៍សហឧក្រិដ្ឋកម្មរួម ហើយពុំមានភាគីណាមួយជំទាស់ឡើយ, *សំណុំរឿង កាំង ហ្គេកអ៊ាវ* , សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹក, ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩, លេខឯកសារ E1/3.1, ទំព័រ ៩-១៣។

[២០] *សូមមើល* ឧបសម្ពន្ធ ២។

ចោទពុំដឹងមុនថាគោលការណ៍នេះជាបទល្មើស គឺជាសាលដីកាមួយដ៏មានលក្ខណៈជាប្រវត្តិសាស្ត្រ[២១]។ លោក Wolfgang Schomburg អតីតចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលនៅតុលាការICTY/ICTR បានចាត់ទុកថាសាលដីការបស់អង្គបុរេជំនុំជម្រះគឺជាសាលដីកាដែល "មានតម្លៃគួរគោរព ត្រង់ថាសាលដីកានេះបានវិភាគល្អិតល្អន់ទៅលើសេចក្តីសម្រេចនានារបស់តុលាការនៅក្រោយសម័យសង្គ្រាមលោកលើកទី២"[២២]។ ចំណែកលោកសាស្ត្រាចារ្យ Jens David Ohlin នៃសាកលវិទ្យាល័យច្បាប់ Cornell បានកត់សម្គាល់ថាសាលដីកានេះ "ត្រូវបានតាក់តែងឡើងយ៉ាងល្អ និងមានសំអាងហេតុម៉ត់ចត់"[២៣]។ ត្រង់ចំណុចជាច្រើននៅក្នុងសំណើរបស់ខ្លួន ក.ស.ព ពុំបានអើពើទៅនឹងសំអាងហេតុទាំងប៉ុន្មានរបស់អង្គបុរេជំនុំជម្រះឡើយ។ ក.ស.ព អះអាងថា៖ **ក.** មាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ចែងអំពីការអនុវត្តគោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣មកអនុវត្ត, **ខ.** គោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥

---

[២១] Kevin Jon Heller, *អ.វ.ត.ក ចេញសេចក្តីសម្រេចដ៏មានសារៈសំខាន់លើបញ្ហាសហឧក្រិដ្ឋកម្មរួម* (ECCC Issues a Landmark Decision on JCE III), OPINIO JURIS, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១០។

[២២] Wolfgang Schomburg, *យុត្តិសាស្ត្រលើសហឧក្រិដ្ឋកម្មរួម-ពិនិត្យឡើងវិញបញ្ហាដែលមិនចេះចប់ (Jurisprudence on JCE-Revisiting a Never Ending Story)*, Cambodia Tribunal Monitor, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០, ទំព័រ ១។

[២៣] Jens David Ohlin, *ចេតនារួមប្រព្រឹត្តបទល្មើសក្រោមច្បាប់អន្តរជាតិ* (*Joint Intentions to Commit International Crimes)* ,11 Chi.J.Int'l L. 693, 748 (2011) ("Ohlin, ចេតនារួម")។ សាស្ត្រាចារ្យ Ohlin ក៏បានកត់សម្គាល់ថាអង្គបុរេជំនុំជម្រះ "បានពិនិត្យយុត្តិសាស្ត្រនៅក្នុងសម័យក្រោយសង្គ្រាមលោកលើកទី២ មិនត្រឹមតែសំណុំរឿងដែលតុលាការ ICTY បានលើកឡើងនៅក្នុងសំណុំរឿង Tadic ប៉ុណ្ណោះទេ", ដូចដឹងទំព័រខាងលើ។ ជាការពិត បន្ទាប់ពីសំណុំរឿង Tadic, មានតែអង្គបុរេជំនុំជម្រះមួយគត់ដែលបានវិភាគល្អិតល្អន់ទៅលើច្បាប់យុត្តិសាស្ត្រដែលមានលើកឡើងក្នុងសំណុំរឿង Tadic។ David Scheffer & Anthony Dinh, *សេចក្តីសម្រេចសំខាន់របស់អង្គបុរេជំនុំជម្រះលើសហឧក្រិដ្ឋកម្មរួមសម្រាប់ការទទួលខុសត្រូវជាបុគ្គល,* Cambodia Tribunal Monitor, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០, ទំព័រ ៣។

ដល់ឆ្នាំ ១៩៧៩[២៤]។ **គ.** ជនជាប់ចោទអាចដឹងមុនថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាបទល្មើស និងមានច្បាប់ចែង និង **ឃ.** គោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ស្រប ទៅនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ អំណះអំណាងទាំងប៉ុន្មាន ខាងលើរបស់ ក.ស.ព ពុំមានអ្វីថ្មីឡើយ ពោលគឺត្រូវបានលើកយកមកនិយាយរួចហើយ នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងលក្ខណៈជាបញ្ហាយុត្តាធិការ[២៥]។

### ក. ច្បាប់បង្កើត អ.វ.ត.ក ពុំមានចែងអំពីគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ឡើយ

៨. អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាគោលការណ៍ទទួលខុសត្រូវលើ សហឧក្រិដ្ឋកម្មរួមអាចមានចែងក្នុងមាត្រា ២៩ ក្រោមពាក្យថា "បានប្រព្រឹត្ត"[២៦]។ អង្គជំនុំ ជម្រះទាំងពីរពុំបានលើកយក <u>គោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣</u> មកពិចារណាឡើយ នៅពេលខ្លួនសម្រេចជារួមថា ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងមាត្រា

---

[២៤] មេធាវីការពារក្តីពុំឯកភាពថាការត្រឹមតែសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅ ពេលពាក់ព័ន្ធ ជាការគ្រប់គ្រាន់នោះទេ។ មេធាវីការពារក្តីនៅតែរក្សាជំហររបស់ខ្លួនថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នេះ ចាំបាច់ក៏ត្រូវមានចែងក្នុងច្បាប់កម្ពុជាដែរ ទើបគ្រប់គ្រាន់។ ប៉ុន្តែ យើងសូមមិនលើកបញ្ហានេះនៅពេលនេះទេ ដោយសារ បញ្ហានេះកំពុងរង់ចាំការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានាពេលអនាគត ដែលត្រូវ បានចេញជំនួសឲ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, លេខឯកសារ E51/4, ដែលបានរៀបរាប់អំពីអញ្ញត្រកម្មដោយអនុលោមតាមវិធាន ៨៩ របស់លោក អៀង សារី ដែលថា អ.វ.ត.ក ពុំមានយុត្តាធិការអនុវត្តបទល្មើសក្រោមច្បាប់អន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរ ជាតិ មកលើលោក អៀង សារី ឡើយ។

[២៥] *សូមមើល* ឧបសម្ព័ន្ធ ១។

[២៦] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤៩; សាលក្រមលើសំណុំរឿង ឌុច, កថាខណ្ឌ ៥១១។

២៩។ អង្គបុរេជំនុំជម្រះបានយល់ឃើញថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ និង ទី២ មានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជា ដោយហេតុថាទម្រង់នៃការទទួលខុសត្រូវទាំងពីរនេះ ស្រដៀងទៅនឹងសហចារី ដែលជាប្រភេទមួយនៃការប្រព្រឹត្តិ[២៧]។ ទីបំផុតអង្គបុរេជំនុំជម្រះពុំបានសន្និដ្ឋានដូចគ្នាទេពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣[២៨]។ ចំណុចនេះបង្ហាញថាខុសពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទី២ សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ពុំមែនជាទម្រង់មួយនៃការប្រព្រឹត្តិ ដូចមានចែងក្នុងមាត្រា ២៩ ឡើយ[២៩] ដែលដូចទៅនឹងទស្សនៈរបស់លោកសាស្ត្រាចារ្យ Kai Ambos[៣០], ចៅក្រម Schomburg[៣១] និងអ្នកស្រាវជ្រាវផ្សេងៗ[32]។ ក.ស.ព

[២៧] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤១។

[២៨] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៨៧។

[២៩] គួរកត់សម្គាល់ថា មាត្រា ២៩ ពុំស្រដៀងគ្នាទៅនឹងមាត្រាពាក់ព័ន្ធនៃលក្ខន្តិកៈតុលាការ ICTY, ICTR និង តុលាការពិសេសសម្រាប់សៀរ៉ាឡេអូនឡើយ។ ឃ្លាថា "*ឬផ្សេងពីនេះ បានជួយ និងជំរុញ*" នៅក្នុងលក្ខន្តិកៈតុលាការទាំងនេះ ធ្វើឱ្យគេអាចចាត់ទុកថា លក្ខន្តិកៈទាំងនេះមានចែងអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទោះបីគេពុំចាត់ទុកទម្រង់នេះថាជាទម្រង់មួយនៃការប្រព្រឹត្តិក៏ដោយ។ ប៉ុន្តែខុសពីលក្ខន្តិកៈតុលាការខាងលើ មាត្រា ២៩ បានបែងចែកច្បាស់លាស់រវាងពាក្យថា "បានប្រព្រឹត្ត" និងពាក្យថា "បានជួយ និងជំរុញ"។ មាត្រានេះចែងថាជនសង្ស័យណាមួយដែល "បានមានផែនការញុះញង់បញ្ជា, <u>ប្រព្រឹត្ត, ឬ ជួយ និងជំរុញ</u>ក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្ម" ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។ ដូច្នេះ អ.វ.ត.ក ពុំអាចយកសហឧក្រិដ្ឋកម្មទម្រង់ទី៣ មកអនុវត្តបានឡើយ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នេះពិតជាស្ថិតនៅក្នុងខ្លឹមសារនៃពាក្យថា "បានប្រព្រឹត្ត"។

[៣០] *សំណុំរឿង កាំង ហ្គេកអ៊ាវ*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សារណាមិត្តតុលាការពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨, លេខឯកសារ D99/3/27 ("សារណារបស់ Ambos"), ផ្នែកទីI.3-I.4។

[៣១] Wolfgang Schomburg, *យុត្តិសាស្ត្រលើសហឧក្រិដ្ឋកម្មរួម-ពិនិត្យឡើងវិញបញ្ហាដែលមិនចេះចប់ (Jurisprudence on JCE-Revisiting a Never Ending Story)*, Cambodia Tribunal Monitor, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០, ទំព័រ ៣-៤។

[៣២] យោងតាមបណ្ឌិត Shane Darcy នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សអៀរឡង់, សាកលវិទ្យាល័យជាតិ Ireland Galway, ផ្ទុយខុសស្រឡះពីច្បាប់ព្រហ្មទណ្ឌ និងគោលការណ៍ទូទៅដែលចែងថាលក្ខន្តិកៈព្រហ្មទណ្ឌគួរត្រូវបកស្រាយឱ្យបានម៉ត់ចត់

ពុំបានលើកទឡ្ហីករណ៍ថ្មីណាមួយឡើយ[៣៣] ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនដែលថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ពិតជាមានចែងក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ក្រោមពាក្យថា "បានប្រព្រឹត្ត"។ ជាការឆ្លើយតប មេធាវីការពារក្តីសូមដាក់បញ្ចូលជាឯកសារយោងនូវសារណារបស់ខ្លួនទាំងអស់ដែលមាននាពេលកន្លងមកស្តីពីបញ្ហានេះ[៣៤]។

---

ចំពោះការយល់ថាសហឧក្រិដ្ឋកម្មរួមស្រដៀងទៅនឹង "ការប្រព្រឹត្តិ" ឧក្រិដ្ឋកម្ម "ពុំស្របជាមួយអត្ថន័យនៃពាក្យថា "ការប្រព្រឹត្តិ" ដែលជាការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់ស្តែង ឬការប្រព្រឹត្តិអំពើអកម្មដែលជាបទល្មើសឡើយ", Shane Darcy, *Imputed Criminal Liability and the Goals of International Justice,* 20 Leiden J. Int'l L. 377, 384 (2007) ("Darcy")។ Steven Powles ពន្យល់ថា៖ "យើងងាយយល់ថាដូចម្តេចបានជាគេអាចចោទជនជាប់ពិរុទ្ធពីបទ [សហឧក្រិដ្ឋកម្មរួមទម្រង់ទី១] ថា "បានប្រព្រឹត្ត" បទល្មើសនោះ...។ ប៉ុន្តែ ...យើងពិបាកយល់ថាដូចម្តេចបានជាគេអាចចោទជនជាប់ពិរុទ្ធពីបទបានចូលរួមក្នុង [សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣] ដូចជានៅពេលដែលឧក្រិដ្ឋកម្មនោះពុំស្ថិត *នៅក្នុង* កម្មវត្ថុនៃសហឧក្រិដ្ឋកម្ម ថាពិតជា "បានប្រព្រឹត្តិ" បទល្មើសនោះ នៅពេលដែលជនជាប់ចោទពុំមានចេតនាប្រព្រឹត្តបទល្មើសនោះ និងអាចពុំបានដឹងអំពីបទល្មើសនោះនៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលមានបទល្មើសនោះ", Steven Powles, *Joint Criminal Enterprise: Criminal Liability by Prosecutorial Ingenuity and Judicial Creativity?,* 2 J. Int'l Crim. Just. 606, 611 (2004) ("Powles")។

[៣៣] ត្រង់នេះ ក.ស.ព អះអាងថា៖ **១.** ពាក្យពេចន៍នៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ជាក់ស្តែងស្ទើរតែដូចគ្នាបេះបិទទៅនឹងបទបញ្ញត្តិស្រដៀងនេះនៅក្នុងច្បាប់លក្ខន្តិកៈសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY"), តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR") និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ("SCSL") ដែលបានបកស្រាយពាក្យថា "បានប្រព្រឹត្ត" ថារួមបញ្ចូលទាំងការចូលរួមនៅក្នុងការរៀបចំផែនការ **២.** អ្នកតាក់តែងច្បាប់បង្កើត អ.វ.ត.ក បានដឹងអំពីសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* និងអាចតាក់តែងមាត្រា ២៩ កុំឲ្យស្រដៀងទៅនឹងបញ្ញត្តិតុលាការទាំងប៉ុន្មានខាងលើ ប្រសិនបើពួកគេពុំមានបំណងដាក់បញ្ចូលការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ទៅក្នុងមាត្រានេះ **៣.** ការដាក់បញ្ចូលការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ គឺធ្វើឡើងស្របតាមកម្មវត្ថុ និងគោលបំណងនៃច្បាប់បង្កើត អ.វ.ត.ក, សំណើ កថាខណ្ឌ ១៤-១៦។ ទឡ្ហីករណ៍នេះត្រូវបានលើកឡើងរួចហើយនៅចំពោះមុខអង្គបុរេជំនុំជម្រះ, *សូមមើល* ឧបសម្ព័ន្ធ ១ ។

[៣៤] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ជំទាស់ទៅនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីការយកទម្រង់នៃការទទួលខុសត្រូវ ដែលហៅថា សហឧក្រិដ្ឋកម្មរួម មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០, លេខឯកសារ D97/4/5 ("បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ៦៦-៧១, និងឧបសម្ព័ន្ធ ក, ផ្នែក II.ខ, សារណាតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង

## ខ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពុំមានចែងអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទេ

### i. អង្គជំនុំជម្រះសាលាដំបូង ពុំគួរអនុវត្តតាមគំរូរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង *Tadic* ឡើយ

៩. អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ប្រភពឯកសារច្បាប់ដែលតុលាការនៅក្នុងសំណុំរឿង *Tadic* លើកយកមកសំអាង ពាក់ព័ន្ធនឹង [សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣]...ពុំបានផ្តល់ភស្តុតាងគ្រប់គ្រាន់អំពីទម្លាប់អនុវត្តន៍ដ៏សង្គតិភាពរបស់រដ្ឋ ឬ*ទស្សនៈគតិយុត្តិ* នៅពេលវេលាពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ឡើយ"[៣៥]។ ក.ស.ព ពុំបានលើកឡើងនូវសំអាងហេតុនេះឡើយ នៅពេលខ្លួនអះអាងថាអង្គជំនុំជម្រះសាលាដំបូង គួរអនុវត្តតាមវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* ដោយហេតុថាពុំមានវិវត្តន៍ជាដុំកំភួននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិឡើយក្នុងចន្លោះពីឆ្នាំ ១៩៧៥ មកទល់នឹងពេលបង្កើតតុលាការ ICTY នៅឆ្នាំ១៩៩៣[៣៦]។ ដំណើរវិវត្តន៍នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុង

---

សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, លេខឯកសារ D97/14/14 ("សារណាតបស្តីពីសហឧក្រិដ្ឋកម្មរួម"), កថាខណ្ឌ ៤០-៥០, សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨, លេខឯកសារ D97/7 ("សេចក្តីសង្កេតបន្ថែម"), កថាខណ្ឌ ១១-១៩, ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨, លេខឯកសារ D97 ("បណ្តឹងជំទាស់នឹងសហឧក្រិដ្ឋកម្មរួម"), កថាខណ្ឌ ៦។

[៣៥] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៧។

[៣៦] សំណើសុំ, កថាខណ្ឌ ២០។ នៅត្រង់ជើងទំព័រមួយ ក.ស.ព អះអាងថា "ជំហររបស់តុលាការ ICTY ទៅលើសហឧក្រិដ្ឋកម្មរួម ត្រូវបានបញ្ជាក់នៅក្នុងសំណុំរឿងក្រោយៗនៅឯតុលាការ ICTY និង ICTR, SCSL និងតុលាការពិសេសសម្រាប់លីបង់ ("STL")"។ *ដូចជើងទំព័រលេខ ២៦*។ ក្នុងចំណោម តុលាការខាងលើ គ្មានតុលាការណាមួយបានពិចារណាអំពីឋានៈនៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ។ មានតែអង្គបុរេជំនុំជម្រះមួយគត់ដែលបានវិភាគជាប្រព័ន្ធទៅលើយុត្តិសាស្ត្រសម័យ

ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩៣ ពុំពាក់ព័ន្ធឡើយ។ បញ្ហាដែលត្រូវសម្រេចគឺថាតើទម្លាប់អនុវត្តន៍របស់រដ្ឋជាទូទៅ និងប្រកបដោយសង្គតិភាព ឬក្រួមជាមួយនឹង *ទស្សនៈគតិយុត្តិ* ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មានចែងក្នុងច្បាប់ពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៣៧]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថាការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពុំមានចែងក្នុងច្បាប់ឡើយ[៣៨] ដែលដូចទៅនឹងការសិក្សាស្រាវជ្រាវមួយរបស់ Max Planck[៣៩]។ ការគ្មានចេតនាដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ទៅក្នុងច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះបីច្បាប់លក្ខន្តិកៈនេះត្រូវបានតាក់តែងយ៉ាងល្អិតល្អន់អស់ពេលជាយូរ និងមានយុត្តិសាស្ត្របន្តបន្ទាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានបដិសេធមិនទទួលស្គាល់សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ គឺជាភស្តុតាងបញ្ជាក់ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពុំមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ

---

សង្គ្រាមលោកលើកទី២។ ភាគច្រើន តុលាការផ្សេងៗពុំបានពិចារណាថាតើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ពិតជាមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ ឬយ៉ាងណានោះទេ ពោលគឺគ្រាន់តែបានយកសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណុំរឿង *Tadic* មកអនុវត្តតាមដោយឥតសង្ស័យ។ ពិសេស យើងពុំអាចលើកយកសំណុំរឿងនៅតុលាការពិសេសសម្រាប់លីបង់ មកធ្វើជាសំអាងបានឡើយដោយហេតុថាចៅក្រម Cassese ដែលជាប្រធានតុលាការនេះ គឺជាអ្នកផ្តួចផ្តើមឲ្យមានការយកការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមមកអនុវត្តនៅក្នុងសាលដីការបស់តុលាការកំពូលក្នុងសំណុំរឿង*Tadic* ។ ចំណុចនេះពុំគាំទ្រដល់អំណះអំណាងរបស់ ក.ស.ព ដែលថាសហឧក្រិដ្ឋកម្មរួមទម្រង់ ៣ ពិតជាមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

[៣៧] *សំណុំរឿង* Fisheries Juridiction Case, អង្គសេចក្តី, 1974 ICJ Rep. 3 at 50; *សំណុំរឿង* North Sea Continental Shelf, អង្គសេចក្តី, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៩, ICJ Rep. 3, កថាខណ្ឌ ៧៧។

[៣៨] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៧។

[៣៩] *សូមមើលទំព័រខាងក្រោយ* កថាខណ្ឌ ២១ ដែលនិយាយអំពីការសិក្សាស្រាវជ្រាវរបស់ Max Planck ក្រោមការឧបត្ថម្ភរបស់ការិយាល័យរដ្ឋអាជ្ញានៃតុលាការ ICTY។

សូម្បីតែរហូតមកទល់នឹងពេលបច្ចុប្បន្ន។ មេធាវីការពារក្តីសូមដាក់បញ្ចូលជាឯកសារយោងនូវសារណារបស់ខ្លួន ដែលមាននាពេលកន្លងមកស្តីពីបញ្ហានេះ[៤០]។

**ii. ពុំមានឡើយ "Grotian moment" ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មទម្រង់ទី ៣ ក្រោយសង្គ្រាមលោកលើកទី ២**

១០. អង្គបុរេជំនុំជម្រះបានបដិសេធទាំងស្រុង[៤១] នូវអំណះអំណាងរបស់ ក.ស.ព ដែលថា មាន "Grotian Moment" ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ក្រោយសង្គ្រាមលោកលើកទី២[៤២]។ Grotian Moment គឺជាពេលមួយដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិលេចចេញជារូបរាងលឿនខុសធម្មតា។ ទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចកើតចេញពី Grotian Momentក្តី ក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថាវាបានកើតឡើងស្របគ្នាជាមួយគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ឡើយ។ មេធាវីការពារក្តីសូមដាក់បញ្ចូលជាឯកសារយោងនូវសារណាទាំងអស់របស់ខ្លួនដែលមាននាពេលកន្លងមកស្តីពីបញ្ហានេះ[៤៣]។

---

[៤០] *សូមមើល* បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤៣, ៤៩-៥៨។ សារណាតបស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ២០,២៣,៤៣,៤៥។ ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី ស្នើសុំដាក់ទណ្ឌកម្មទៅលើសហព្រះរាជអាជ្ញា ដែលបាននាំឱ្យតុលាការភ័ន្តច្រឡំនៅក្នុងសេចក្តីសង្កេតបន្ថែមរបស់ខ្លួនស្តីពីសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩, លេខឯកសារ D97/9/4, សេចក្តីសង្កេតបន្ថែម, កថាខណ្ឌ ៣០-៥៤, បណ្តឹងជំទាស់នឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ១៨-២៣។

[៤១] ក.ស.ព បានលើកទឡ្ហីករណ៍នេះជូនអង្គបុរេជំនុំជម្រះ នៅក្នុងចម្លើយរួមរបស់សហព្រះរាជអាជ្ញាតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផនស្តីពីសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១០, លេខឯកសារ D97/16/5, កថាខណ្ឌ ៣៤។ អង្គបុរេជំនុំជម្រះពុំបានលើកឡើងនូវទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាឡើយដោយបញ្ជាក់ថាទឡ្ហីករណ៍នេះពុំមានលក្ខណៈគួរឱ្យ អ.ប.ជ ជឿជាក់។

[៤២] សំណើសុំ, កថាខណ្ឌ ២១។

[៤៣] *សូមមើល* ចម្លើយតបស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ២១។

iii. សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ពុំមានចែងឡើយ នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ, ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ឬច្បាប់ក្រុមប្រឹក្សា ត្រួតពិនិត្យលេខ ១០

១១. អង្គបុរេជំនុំជម្រះបានយល់ឃើញថាសញ្ញាណនៃការទទួលខុសត្រូវលើផែនការរួម ដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ "គឺជាភស្តុតាងពុំអាចប្រកែកបាន" ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និង ទី២ ពិតជាបានមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិប្រាកដមែន[៤៤]។ ប៉ុន្តែពាក់ព័ន្ធនឹងការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣វិញ អង្គបុរេជំនុំជម្រះបានយល់ថា "ធម្មនុញ្ញតុលាការ Nuremberg និងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ <u>ពុំគាំទ្រ</u> ទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួមឡើយ (សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣)"[៤៥]។ សូម្បីអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* ក៏<u>ពុំបាន</u>យកលិខិតុបករណ៍ទាំងអស់នោះមកធ្វើជាសំអាងឡើយ នៅពេលពិចារណាថាតើការទទួលខុសត្រូវលើ<u>សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣</u> មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬទេ។ ក.ស.ព ពុំបានអើពើទៅនឹងសំអាងហេតុរបស់អង្គបុរេជំនុំជម្រះឡើយ ដោយបានយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ និង ទី២ បញ្ចូលជាមួយសហាក្រិដ្ឋកម្មរួមទម្រង់ទី៣ ដោយបានអះអាងថាគោលការណ៍ទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មាននៅក្នុងសញ្ញាណនៃផែនការរួម ដែលមានចែងនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ, តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា និងច្បាប់

---

[៤៤] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៥៧-៥៨។

[៤៥] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៧៨។ *សូមមើលផងដែរ* Darcy,ត្រង់ទំព័រ ៣៨៤៖ "មានភាពមន្ទិលដែលថារដ្ឋមួយចំនួនតូចដែលបានប្រើប្រាស់ទម្រង់ពង្រីកបន្ថែមស្តីពីការទទួលខុសត្រូវលើផែនការរួមកាលពីពេលនោះ បានផ្តល់ឋានៈជាច្បាប់ទំនៀមទម្លាប់ដល់ទម្រង់នៃការទទួលខុសត្រូវមួយនេះ, ពិសេសដោយយល់ថាគ្មានសន្ធិសញ្ញាណាមួយដែលបានអនុម័តក្នុងសម័យក្រោយសង្គ្រាម បានទទួលស្គាល់ទស្សនទាននេះ"។

ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០[៤៦]។ រាល់លិខិតុបករណ៍ទាំងនេះពុំបានគាំទ្រអំណះអំណាងរបស់ ក.ស.ព ដែលថាគោលការណ៍ទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពិតជាមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

### iv. គោលការណ៍សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពុំត្រូវបានប្រើប្រាស់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិនៅក្រោយសម័យសង្គ្រាមលោកលើកទី២ ឡើយ

១២. អង្គបុរេជំនុំជម្រះបានយល់ឃើញថាសំណុំរឿង *Borkum Island* និងសំណុំរឿង *Essen Lynching* ដែល ក.ស.ព លើកយកមកធ្វើជាសំអាង "ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់អំពីទម្លាប់អនុវត្តន៍ប្រកបដោយសង្គតិភាពរបស់រដ្ឋ ឬ*ទស្សនៈគតិយុត្តិ* " ដើម្បីសន្និដ្ឋានថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ពិតជាបានមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ ១៩៤៩ ដល់ឆ្នាំ ១៩៧៥ ឡើយ[៤៧]។ ការវិភាគល្អិតល្អន់ទៅលើសំណុំរឿងទាំងនេះ គឺជាបង្អែកដល់ការយល់ឃើញដូចខាងលើរបស់អង្គបុរេជំនុំជម្រះ។

១៣. អង្គបុរេជំនុំជម្រះបានលើកយកអង្គហេតុនៃសំណុំរឿង *Borkum Island* មកធ្វើការពិនិត្យពិចារណា[៤៨]។ ក្នុងសំណុំរឿងនេះ ជនជាប់ចោទទាំងអស់សុទ្ធតែរងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម "ជាពិសេសទាំងបទ "លើកទឹកចិត្ត, ជួយផ្តល់មធ្យោបាយ, ជំរុញ និងចូលរួមនៅក្នុងការសម្លាប់ដ៏ព្រៃផ្សៃដោយចេតនា និងខុសច្បាប់ទៅលើទ័ពអាកាស និងពីបទលើកទឹកចិត្ត,ជួយផ្តល់មធ្យោបាយ,ជំរុញ និងចូលរួមក្នុងការវាយប្រហារដោយព្រៃផ្សៃដោយចេតនា

---

[៤៦] សំណើសុំ, កថាខណ្ឌ ២៣។

[៤៧] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៧៧ (បញ្ជាក់បន្ថែម)។

[៤៨] *ដូចជើងទំព័រខាងលើ, ជើងទំព័រលេខ ២២៧*។

និងខុសច្បាប់ទៅលើទ័ពអាកាស””[៤៩]។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* បានសន្និដ្ឋាន ដោយពុំមានសំអាងហេតុថាជនជាប់ចោទទាំងអស់ដែលតុលាការបានរកឃើញពិរុទ្ធភាព គឺជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការឧក្រិដ្ឋរួម (ចេតនាធ្វើបាបទ័ពអាកាស) ប៉ុន្តែជនជាប់ចោទមួយចំនួនទៀតក៏ត្រូវបានតុលាការរកឃើញថាមានទោសពីមនុស្សឃាតដោយចេតនាផងដែរ សូម្បីតុលាការកំពូលគ្មានភស្តុតាងបញ្ជាក់ថាពួកគេពិតជាបានសម្លាប់អ្នកទោសទាំងអស់នោះក្តី ដោយហេតុថាពួកគេស្ថិតក្នុងស្ថានភាពមួយអាចដឹងមុនថា ការធ្វើបាបនោះមុខជានាំទៅដល់ការសម្លាប់ទ័ពអាកាសទាំងអស់នោះ ពីសំណាក់ហ្វូងមនុស្សដែលបានចូលរួមក្នុងការធ្វើបាបជាក់ជាមិនខាន[៥០]។ អង្គបុរេជំនុំជម្រះ ពុំបានឯកភាពទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* ឡើយ ត្រង់ចំណុចដែលថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ត្រូវបានអនុវត្ត “យោងទៅតាមអំណះអំណាងរបស់រដ្ឋអាជ្ញា ដែលថា ជនជាប់ចោទទាំងអស់មានចេតនាចង់ឲ្យជនរងគ្រោះស្លាប់, តុលាការអាចជឿជាក់ថា បុគ្គលទាំង៦នាក់នេះក៏មានចេតនាចង់ឲ្យជនរងគ្រោះស្លាប់ផងដែរពោលគឺពួកគេពុំមែនត្រឹមតែអាចដឹងថាជនរងគ្រោះ អាចស្លាប់នោះឡើយ”[៥១]។

[៤៩] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៧៩។

[៥០] *ដូចជើងទំព័រខាងលើ*។

[៥១] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៨០ (មានការសង្កេតសេចក្តីបន្ថែម)។ សាស្ត្រាចារ្យ Ohlin បានពន្យល់ថា៖ “ទោះបីអង្គហេតុនៃសំណុំរឿងនេះ ពាក់ព័ន្ធផ្ទាល់ទៅនឹងការពិភាក្សាអំពីសហឧក្រិដ្ឋកម្មរួមក្តី ក៏តុលាការយោធាបានចេញសាលក្រមផ្តន្ទាទោសយ៉ាងសាមញ្ញ ដោយគ្មានសំអាងហេតុជាដុំកំភួនស្តីពីបញ្ហាផែនការឧក្រិដ្ឋរួម ឬការវាយដំពីសំណាក់ហ្វូងមនុស្ស។ ដូច្នេះ តុលាការក្នុងសំណុំរឿង *Tadic* បានដកស្រង់ពាក្យពេចន៍របស់រដ្ឋអាជ្ញានៃតុលាការយោធាសហរដ្ឋអាមេរិក ហើយបាន *សន្និដ្ឋាន* ថា ចៅក្រមបានជ្រើសរើសយកសំអាងហេតុរបស់រដ្ឋអាជ្ញា។ ករណីបែបនេះជាការធ្វេសប្រហែស។ ជាការពិត ការពិភាក្សារបស់រដ្ឋអាជ្ញាអំពីបញ្ហានេះមានភាពមិនចុះសម្រុងគ្នាផ្ទៃក្នុង”, Jens David Ohlin, (បញ្ហាទស្សនទានទាំង ៣ ពាក់ព័ន្ធនឹងគោលការណ៍សហឧក្រិដ្ឋកម្មរួម) *Three Conceptual Problems with the Doctrine of Joint Criminal Enterprise, 5 J. Int’l Crim. Just. 69, 75, n. 10 (2007) (“Ohlin, បញ្ហាទស្សនទានទាំង៣)*។

១៤. ក្នុងការលើកយកសំណុំរឿង *Essen Lynching* មកពិចារណា អង្គបុរេជំនុំជម្រះក៏បានពិនិត្យឡើងវិញទៅលើអង្គហេតុនៃសំណុំរឿងនេះ ព្រមទាំងបទចោទ និងទឡ្ហីករណ៍របស់ភាគី។ បន្ទាប់មកអង្គបុរេជំនុំជម្រះបានយល់ឃើញថា "ក្នុងសំណុំរឿងនេះ ពុំមានចំណុចណាមួយបញ្ជាក់ថា រដ្ឋអាជ្ញាពិតជាបានផ្អែកអំណះអំណាងទៅលើទស្សនទានស្ដីពីផែនការរួមឡើយ ហើយសំណុំរឿងមួយនេះពុំអាចឱ្យគេយល់ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ពិតជាមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"[៥២]។

១៥. អ្នកសិក្សាស្រាវជ្រាវជាច្រើននាក់បានឯកភាពថាសំណុំរឿងទាំងអស់ខាងលើ ពុំអាចសបញ្ជាក់ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ពិតជាមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[៥៣]។ ដូចដែលសាស្ត្រាចារ្យ Ohlin បានពន្យល់យ៉ាងក្បោះក្បាយថា៖

[៥២] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៨១។ Powles ពន្យល់ថា៖ "តាមការកត់សម្គាល់របស់របស់អង្គជំនុំជម្រះតុលាការកំពូល, រដ្ឋអាជ្ញាក្នុងសំណុំរឿង *Essen Lynching* បានបញ្ជាក់ថាប្រសិនបើជនជាប់ចោទមាន*ចេតនា*សម្លាប់ ពួកគេនឹងមានទោសពីបទមនុស្សឃាតដោយចេតនា។ ប៉ុន្តែប្រសិនបើជនជាប់ចោទគ្មានចេតនាសម្លាប់ ពួកគេនឹងជាប់ទោសពីបទមនុស្សឃាតដោយអចេតនា។ ជនជាប់ចោទត្រូវតុលាការសម្រេចផ្ដន្ទាទោសពីបទមនុស្សឃាតដោយចេតនា ដែលមានន័យថាតុលាការបានសន្និដ្ឋានថាជនជាប់ចោទទាំងអស់បានមានចេតនាចង់ឱ្យអ្នកបើកយន្តហោះស្លាប់។ ដូច្នេះអាចមានការចោទសួរមួយថាតើតុលាការក្នុងសំណុំរឿង *Essen Lynching* ពិតជាបានសម្រេចឱ្យជនដែលពុំមានចេតនាពិតប្រាកដក្នុងការសម្លាប់អ្នកបើកយន្តហោះ ពីបទមនុស្សឃាតដោយចេតនា", Powles, ត្រង់ទំព័រ ៦១៥-៦១៦។

[៥៣] *សូមមើលសំណុំរឿង កាំង ហ្គេកអ៊ាវ*, សំណុំរឿងលេខ 00១/១៨-0៧-២00៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ 0២), សារណាមិត្តតុលាការដាក់ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងទ្រឹស្តីពហុនិយមនៃច្បាប់, សាកលវិទ្យាល័យ McGill, ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៨, លេខឯកសារ D99/3/25 ("សារណារបស់ McGill"), កថាខណ្ឌ ២២-២៤, សារណារបស់ Ambos, ផ្នែកទី II.៣.៣។ បណ្ឌិត Kevin Joh Heller, ដែលកន្លងទៅថ្មីៗ បានបោះពុម្ពផ្សាយសៀវភៅមួយក្បាលក្រោមចំណងជើងថា "តុលាការយោធា Nuremberg និងប្រភពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (The Nuremberg Military Tribunals and The Origins of International Criminal Law) បានអះអាងនៅក្នុងគេហទំព័រ ទស្សនៈនៃច្បាប់ថា "គ្មានអ្វីចម្លែកឡើយដែលនាពេលថ្មីៗ អ.វ.ត.ក មិនទទួលស្គាល់ទាំងស្រុងនូវទស្សនទានស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ បន្ទាប់

បញ្ហាទីមួយពាក់ព័ន្ធនឹងសំណុំរឿងទាំងអស់នេះគឺថា គ្មានសំណុំរឿងណាមួយមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ចៅក្រមឡើយ ពោលគឺមានតែសារណាជាលាយលក្ខណ៍អក្សររបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប៉ុណ្ណោះ។ ផ្អែកទៅលើការសម្រេចរបស់ចៅក្រមក្នុងការចេញសាលក្រមផ្តន្ទាទោស យើងអាចសន្មតថាតុលាការបានឯកភាពតាមគំនិតរបស់រដ្ឋអាជ្ញា។ នេះជាបញ្ហាផ្នែកសំអាងហេតុសុទ្ធសាធ។ បញ្ហាទីពីរដែលជាបញ្ហាសំខាន់គឺថាក្នុងសំណុំរឿងទាំងអស់នោះពុំមានចំណុចណាមួយ ដែលបញ្ជាក់ថាជនជាប់ចោទពិតជាបានឯកភាពទៅនឹងផែនការឧក្រិដ្ឋឡើយ ប៉ុន្តែជនជាប់ចោទបែរជាត្រូវតុលាការផ្តន្ទាទោសដោយសារទង្វើរបស់អ្នកសមគំនិត ដែលបានប្រព្រឹត្តហួសពីវិសាលភាពនៃផែនការឧក្រិដ្ឋទៅវិញ។ ការសម្លាប់ជនរងគ្រោះទាំងនោះគឺការជាសម្លាប់ក្រៅប្រព័ន្ធច្បាប់ ប៉ុន្តែតុលាការបែរជាទុកឲ្យជនជាប់ចោទទាំងនោះជាអ្នកទទួលខុសត្រូវទៅវិញ ទោះបីរដ្ឋអាជ្ញាពុំមានភស្តុតាងបញ្ជាក់ថាអ្នកណាជាអ្នកសម្លាប់នរណា (ដោយផ្ទាល់ដៃ) ក៏ដោយ ។ ជាការពិតជាក់ស្តែង នៅក្នុងឯកសារស្តីពីទស្សនៈរបស់តុលាការក្នុងសំណុំរឿង *Tadic* តុលាការពុំបានលើកយកសំណុំរឿង *អន្តរជាតិ* ណា ដែលនិយាយអំពីការទទួលខុសត្រូវលើទង្វើដែលជនជាប់ចោទអាចដឹងមុនដោយមានហេតុផលសមស្រប មកធ្វើជាសំអាងឡើយ ពោលគឺសូម្បីតែមួយក៏គ្មានដែរ[៥៤]។

---

ពីបានពិនិត្យសំណុំរឿងនានាដែលសំណុំរឿង *Tadic* បានលើកយកមកសំអាងដើម្បីការពារទស្សនទានមួយនេះ! ជាមួយកំហុសបែបនេះ តើយើងអាចទុកចិត្តខ្លឹមសារនៃសេចក្តីសម្រេចនេះដូចម្តេចទៅ?"។ បណ្ឌិត Heller ចង់ និយាយសំដៅទៅដល់ការដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង *Tadic* បានដកស្រង់យកទឡ្ហីករណ៍បញ្ចប់ការពិភាក្សាដេញដោលទៅដាក់បញ្ចូលក្នុងសាលក្រមរបស់តុលាការនេះ ក្នុងការពិភាក្សាអំពីសំណុំរឿង *Einsatzgruppen*។ Kevin Jon Heller, *កំហុសដ៏សែនធំមួយនៅក្នុងសំណុំរឿង Tadic (An Egregious Error in Tadic)*, Opinio Juris, ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១០។

[៥៤] Ohlin, *ចេតនារួម*, ត្រង់ទំព័រ ៧០៨។

១៦. ទោះបីអង្គបុរេជំនុំជម្រះពុំបានពិចារណាករណីនេះជាពិសេសយ៉ាងណាក្តី ក៏នៅមានឧទាហរណ៍ពីករណីក្រោយសង្គ្រាមលោកលើកទី ២ មួយចំនួនផងដែរ ក្នុងនោះការទទួលខុសត្រូវនៃទម្រង់ទី៣នៃសហឧក្រិដ្ឋកម្ម មិនត្រូវបានយកមកអនុវត្តទេ។ តាមពិត ការដែលគេមិនបានអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី ៣ ឲ្យស្របគ្នានៅក្នុងករណីទាំងនេះ សបញ្ជាក់ឲ្យឃើញថា គេមិនបានបង្កើតវាទៅជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ សហមេធាវីការពារក្តី ដាក់បញ្ចូលសារណាតាមផ្លូវតុលាការមុនៗរបស់ខ្លួនពាក់ព័ន្ធនឹងករណីនេះដើម្បីធ្វើជាឯកសារយោង[៥៥] ។

១៧. អង្គបុរេជំនុំជម្រះរកឃើញថា អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានពឹងផ្អែកមិនត្រឹមត្រូវលើសំណុំរឿងតុលាការអ៊ីតាលី ដែលពុំមានការផ្សព្វផ្សាយ យកមកធ្វើជាការគាំទ្របន្ថែម ដើម្បីសន្និដ្ឋានថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ករណីទាំងនេះពុំមែនជា“ករណីយុត្តិសាស្ត្រដ៏ត្រឹមត្រូវសម្រាប់គោលបំណងក្នុងការសម្រេចអំពីឋានៈ នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ...”[៥៦] នោះឡើយ។ សហមេធាវីការពារក្តីយល់ស្រប និងសូមដាក់បញ្ចូលសារណាតាមផ្លូវតុលាការមុនៗរបស់ខ្លួនពាក់ព័ន្ធនឹងករណីនេះដើម្បីធ្វើជាឯកសារយោង[៥៧]។ ការិយាល័យសហព្រះរាជអាជ្ញាមើលទៅដូចជាយល់ស្របដូច្នេះដែរ។ ការិយាល័យសហព្រះរាជអាជ្ញា មិនបានពឹងផ្អែកលើប្រភពទាំងនេះ ដើម្បីបង្ហាញច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ប៉ុន្តែខ្លួនគ្រាន់តែចាត់ទុកវាថាជាភ័ស្តុតាងសន្និដ្ឋាន នៃគោលការណ៍ទូទៅមួយរបស់ច្បាប់ប៉ុណ្ណោះ[៥៨]។ ការណ៍ដែលការិយាល័យសហព្រះរាជអាជ្ញា អះអាងថា ការទទួលខុសត្រូវនៃផែនការរួម បូកបញ្ចូលទាំងសហឧក្រិដ្ឋ

---

[៥៥] *សូមមើល* បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤៦; សេចក្តីសង្កេតបន្ថែម កថាខណ្ឌ ៤៥-៥៣; បណ្តឹងជំទាស់នឹងសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២៤។

[៥៦] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២។

[៥៧] *សូមមើល* បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ ៤០; សេចក្តីសង្កេតបន្ថែម កថាខណ្ឌ ៥៩។

[៥៨] សំណើសុំ កថាខណ្ឌ ២៩។

កម្មរួមទម្រង់ទី ៣ យកអនុវត្តនៅក្នុងយុត្តិសាស្ត្រអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២[៥៩] គឺជាការភ័ន្តច្រឡំមួយ។

**iv. កម្មវត្ថុ និងគោលបំណងនៃធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិIMT និង ការជំនុំជម្រះក្តីទាំងឡាយក្រោយសង្គ្រាមលោកលើកទី ២ មិនគាំទ្រការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣**

១៨. ការិយាល័យសហព្រះរាជអាជ្ញា អះអាងថា សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថាសហឧក្រិដ្ឋរួមទម្រង់ទី ៣ ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ គឺមានហេតុផលសមស្រប ដោយសម្អាងលើកម្មវត្ថុ និងគោលបំណងនៃធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិ និងការជំនុំជម្រះក្តីក្រោយសង្គ្រាមលោកលើកទី ២[៦០]។ ប៉ុន្តែ ការិយាល័យសហព្រះរាជអាជ្ញា ពុំបានបញ្ជាក់ថាករណីនេះដូចគ្នានោះទេ ដ្បិត ជាពិសេស ការជំនុំជម្រះក្តីក្រោយសង្គ្រាមលោកលើកទី ២ ដែលការិយាល័យសហព្រះរាជអាជ្ញា យកមកធ្វើជាសម្អាងនោះ ពុំបានបង្ហាញថាការទទួលខុសត្រូវក្នុងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានគេយកមកអនុវត្តនោះទេ។ មិនតែប៉ុណ្ណោះ កម្មវត្ថុ និង គោលបំណងនោះ ទោះបីវាគាំទ្រទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមយ៉ាងណាក្តី ក៏ពុំមែនជាការសមស្របដើម្បីយកវាមកពិចារណាជំនួសការអនុវត្តរបស់រដ្ឋ និង *ទស្សនៈគតិយុត្តិ (opinio juris)*[៦១] បាននោះទេ។

## គ. ទម្រង់ទី៣នៃសហឧក្រិដ្ឋរួម គ្មានជាគោលការណ៍ទូទៅនៃច្បាប់ ក្នុង ឆ្នាំ ១៩៧៥-៧៩

---

[៥៩] ដូចខាងលើ កថាខណ្ឌ ២៣។

[៦០] ដូចខាងលើ។

[៦១] ដើម្បីជ្រាបច្បាស់នូវសេចក្តីពន្យល់មែនទែន នៃសម្អាងហេតុដែលខុសឆ្គងរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿង *Tadić* ដែលពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃលក្ខន្តិកៈរបស់តុលាការ ICTY *សូមមើល* Ohlin, *Three Conceptual Problems* ត្រង់ចំណុច ៧២។ ទឡ្ហីករណ៍នេះ អាចយកមកអនុវត្តបានដូចគ្នា ដើម្បីពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃលិខិតុបករណ៍អន្តរជាតិ ដែលការិយាល័យសហព្រះរាជអាជ្ញាយកជាសម្អាង។

១៩. អង្គបុរេជំនុំជម្រះ យល់ឃើញថា "ឋានៈពិតប្រាកដនៃគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ជាប្រភពជំនួយ ឬ ប្រភពសំខាន់នៃច្បាប់អន្តរជាតិ គឺមានលក្ខណៈមិនច្បាស់ឡើយ"[៦២]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* យល់ឃើញថា "ច្បាប់ជាតិទាំងនេះ [ខ្លួនបានពិនិត្យឡើងវិញរួច] មិនអាចត្រូវបានយកមកធ្វើជាភ័ស្តុតាងសំអាងដែលមិនអាចបដិសេធបាន" ដែលថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម បង្កើតបានជាគោលការណ៍ទូទៅនៃច្បាប់នោះទេ[៦៣]។ ការិយាល័យសហព្រះរាជអាជ្ញា ពុំបាន

---

[៦២] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៤។ *សូមមើល* BIN CHENG, គោលការណ៍ទូទៅនៃច្បាប់អនុវត្តដោយតុលាការ និងសាលាក្តីអន្តរជាតិ 2-4 (Cambridge University Press 2006)៖ "ខ្លឹមសារនៃ"គោលការណ៍ច្បាប់ ត្រូវបានទទួលស្គាល់ដោយអរិយប្រទេស"... ភ្លាមនោះបង្កអោយមានកិច្ចពិភាក្សាល្អិតល្អន់មួយក្នុងចំណោមអ្នកនិពន្ធ ហើយពួកគាត់មានគំនិតខ្វែងគ្នាច្រើនពាក់ព័ន្ធនឹងចរិតលក្ខណៈនៃគោលការណ៍នេះ។ ពួកគាត់ខ្លះថាពាក្យនេះសំដៅជាសំខាន់ទៅលើគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ...។ ពួកគាត់ខ្លះទៀត យល់ឃើញថាភាពច្រំដែលក្នុងលក្ខន្តិកៈប្រសិនបើតម្រូវឲ្យតុលាការអនុវត្តគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ និងថា ដូច្នេះបទប្បញ្ញត្តិនេះ អាចយោងបានតែចំពោះគោលការណ៍ក្នុងច្បាប់ជាតិប៉ុណ្ណោះ... អ្នកនិពន្ធពុំបានយល់ស្របថាតើ"គោលការណ៍ទូទៅនៃច្បាប់"ជាផ្នែកមួយនៃបទបញ្ញត្តិច្បាប់អន្តរជាតិ ដោយសារតែវាជាវិធានច្បាប់ ឬ ដោយសារតែមានវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទើបគោលការណ៍នេះអាចអនុវត្តបានក្នុងទំនាក់ទំនងអន្តរជាតិឬយ៉ាងណានោះទេ។ មិនតែប៉ុណ្ណោះ អ្នកនិពន្ធខ្លះ ប្រកាន់ជំហរថា"គោលការណ៍ទូទៅនៃច្បាប់" មិនអាចបង្កើតជាផ្នែកមួយនៃច្បាប់អន្តរជាតិដែលមានស្រាប់បាននោះទេ ប៉ុន្តែវាអាចបង្កើតបានជាផ្នែកមួយនៃច្បាប់ដែលអនុវត្តដោយតុលាការពិភពលោក តាមរយៈការបញ្ចូលបទប្បញ្ញត្តិក្នុងលក្ខន្តិកៈ។ <u>បញ្ហាទស្សនៈខ្វែងគ្នាធំបំផុត គឺពាក់ព័ន្ធនឹងផ្នែកដែលត្រូវបំពេញក្នុងច្បាប់អន្តរជាតិ ដោយ "គោលការណ៍ទូទៅ" ទាំងនេះ</u>។ (បញ្ជាក់បន្ថែម)។

[៦៣] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៥ *ដកស្រង់ពីករណី ព្រះរាជអាជ្ញា ទល់នឹង Tadić*, IT-94-1-A, សាលដីកា, ("សាលដីកាតុលាការកំពូល *Tadić* ") កថាខណ្ឌ ២២៥ ដែលចែងថា "គួរបញ្ជាក់ថាសេចក្តីយោងទៅច្បាប់ជាតិ និងយុត្តិសាស្ត្រនោះ គឺគ្រាន់តែធ្វើឡើងដើម្បីបង្ហាញថា គោលគំនិតនៃគោលបំណងរួមដែលច្បាប់ព្រហ្មទណ្ឌអន្តរជាតិទទួលស្គាល់ មានមូលដ្ឋានក្នុងច្បាប់ជាតិជាច្រើន។ <u>ផ្ទុយទៅវិញ ផ្នែកដែលបានពិភាក្សាគ្នា ច្បាប់ជាតិ និងយុត្តិសាស្ត្រ **មិនអាច**ពឹង ពាក់អាស្រ័យធ្វើជាប្រភពមួយនៃគោលការណ៍ ឬវិធានអន្តរជាតិបាននោះទេ នៅក្រោមទ្រឹស្តីនៃគោលការណ៍ទូទៅនៃច្បាប់ ដែលបានទទួលស្គាល់ដោយប្រទេសនៃពិភពលោក៖ បើចង់ឲ្យការពឹងពាក់ អាស្រ័យនេះអាចទទួលយកបាន ជាការចាំបាច់គេត្រូវបង្ហាញជាពិសេសថា ប្រទេសទាំងឡាយបានអនុម័តតាមគោលគំនិតនៃគោលបំណង</u>

ពន្យល់អំពីមូលហេតុ ឬ វិធីដែលខ្លួនចាត់ទុកថាប្រភពនៃច្បាប់នេះ អាចអនុវត្តនៅ អវតក ឬ វិធីដែលអង្គបុរេជំនុំជម្រះ ភ័ន្តច្រឡំនៅពេលយល់ឃើញថា ឋានៈនៃគោលការណ៍ទូទៅនៃច្បាប់ មានលក្ខណៈមិនច្បាស់លាស់ នោះឡើយ។ ទោះបី "គោលការណ៍ទូទៅនៃច្បាប់ត្រូវបានទទួលស្គាល់ដោយអរិយប្រទេស" ជាប្រភពមួយនៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់ដោយតុលាការយុត្តិធម៌អន្តរជាតិយ៉ាងណាក្តី[៦៤] ក៏គេនៅតែមិនច្បាស់ ថាវាជាប្រភពសមស្របមួយនៃច្បាប់ សម្រាប់តុលាការជាតិ (ឬ សម្រាប់តុលាការ "ដែលមានលក្ខណៈជាអន្តរជាតិ" មួយ) អនុវត្តបានដោយផ្ទាល់នោះទេ។ សហមេធាវីការពារ សូមអះអាងថា អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច ភ័ន្តច្រឡំ នៅពេលខ្លួនសន្និដ្ឋានថា គេអាចផ្អែកលើប្រភពនៃច្បាប់នេះបាន[៦៥]។ ជាពិសេស គោលការណ៍ទូទៅនៃច្បាប់ មិនអាចអនុវត្តធ្វើជាប្រភពជំនួយ ឬប្រភពសំខាន់នៃច្បាប់នៅ អវតក បានឡើយ។ ទោះបី អង្គបុរេជំនុំជម្រះ យល់ឃើញថាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលយោងទំនៀមទម្លាប់អន្តរជាតិ អនុញ្ញាតឲ្យគេអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅ អវតក បាន[៦៦]យ៉ាងណាក្តី ក៏ខ្លួនមិនបានយល់ឃើញថា ខ្លួនអនុញ្ញាត ឬ បញ្ចូលគោលការណ៍ទូទៅនៃច្បាប់ នោះដែរ។ ដូច្នេះ គោលការណ៍ទូទៅនៃច្បាប់ មិនគប្បីត្រូវបានយកមកអនុវត្តជាមធ្យោបាយ ដើម្បីធ្វើជាមូលហេតុក្នុងការអនុវត្តទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានហាមឃាត់រួចទៅហើយនោះទេ។

---

<u>រួមនេះដូចគ្នា។ ពិសេសជាងនេះទៅទៀត ជាការចាំបាច់ គេត្រូវបង្ហាញថា ជាជានិច្ចជាកាលប្រព័ន្ធច្បាប់សំខាន់នៃពិភពលោកនេះ ត្រូវមានវិធីសាស្ត្រដូចគ្នាទៅនឹងគោលគំនិតនេះ</u>។ ការស្ទង់មតិសង្ខេបខាងលើបង្ហាញ ផ្ទុយពីការអះអាងខាងដើម (បញ្ជាក់បន្ថែម)។

[៦៤] លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ មាត្រា ៣៨(១)(គ) ។

[៦៥] សាលក្រម*ឌុច* កថាខណ្ឌ ៣០។

[៦៦] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៨ ។

២០. អង្គបុរេជំនុំជម្រះ សន្និដ្ឋានថា ខ្លួន "ពុំចាំបាច់សម្រេច" ថាតើទម្រង់ទីបីនៃ សហឧក្រិដ្ឋកម្មរួម បង្កើតបានជាគោលការណ៍ទូទៅមួយនៃច្បាប់ឬយ៉ាងណានោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា "<u>ទោះបីជាបែបនេះក៏ដោយ</u>" ខ្លួន "ពុំយល់ឃើញថា ទម្រង់ទទួលខុសត្រូវបែបនេះ ត្រូវបានជនជាប់ចោទអាចព្យាករណ៍ជាមុន..."[៦៧] នោះទេ។ ឃ្លា"ទោះបីជាបែបនេះក៏ដោយ" គូសបញ្ជាក់ថា ការខ្វះភាពព្យាករណ៍ជាមុន <u>ពុំមែនជាមូលដ្ឋាន</u> សម្រាប់ឲ្យអង្គបុរេជំនុំជម្រះ ពិចារណាថា ខ្លួនពុំចាំបាច់សម្រេចថាតើទម្រង់ទីបីនៃសហឧក្រិដ្ឋរួម គឺជាគោលការណ៍ទូទៅមួយនៃច្បាប់ ដូចអ្វីដែលការិយាល័យសហព្រះរាជអាជ្ញា អះអាងនោះឡើយ[៦៨]។ អង្គបុរេជំនុំជម្រះ បានសន្និដ្ឋានរួចហើយ ថាគេពុំចាំបាច់ពិនិត្យមើលឡើងវិញនូវប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោកនោះទេ ដ្បិត"ប្រព័ន្ធច្បាប់ផ្សេងៗគ្នា មានលក្ខណៈខុសគ្នាពាក់ព័ន្ធនឹងធាតុអត្តនោម័ត ដែលតម្រូវឲ្យភ្ជាប់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅនឹងជនជាប់ចោទ ចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តដោយបុគ្គលផ្សេងទៀត ដែលប្រព្រឹត្តរួមគ្នា ប៉ុន្តែហួសពីអ្វីដែលជនជាប់ចោទប៉ុនប៉ងធ្វើ"[៦៩]។ អង្គបុរេជំនុំជម្រះ យល់ឃើញ(និង សូម្បីតែអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadić* ក៏យល់ឃើញ[៧០]) ថា ប្រព័ន្ធច្បាប់ផ្សេងៗគ្នា មានលក្ខណៈខុសគ្នាពាក់ព័ន្ធនឹងធាតុអត្តនោម័ត ដែលតម្រូវឲ្យភ្ជាប់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅនឹង

---

[៦៧] ដូចខាងលើ កថាខណ្ឌ ៨៧ ។

[៦៨] សំណើសុំ កថាខណ្ឌ ៣០ ។

[៦៩] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៤។ *សូមមើល* Marsh & Michael Ramsden *សហឧក្រិដ្ឋកម្មរួម៖ ការឆ្លើយតបរបស់កម្ពុជាទៅកាន់* Tadić, 11 INT'L CRIM. L. REV. 137, 151 (2011)៖ " អង្គបុរេជំនុំជម្រះ យល់ឃើញថា "អង្គជំនុំជម្រះ ពុំចាំបាច់សម្រេចថាតើប្រព័ន្ធច្បាប់ជាតិជាច្រើន ដែលចាត់ទុកថាតំណាងឲ្យប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោក ទទួលស្គាល់ថាបទដ្ឋាននៃធាតុផ្សំអត្តនោម័តដែលមានកម្រិតទាបជាងចេតនា អាចអនុវត្តបានពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្រៅវង្វង់នៃគោលបំណងឧក្រិដ្ឋរួមឬយ៉ាងណានោះទេ..."។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើងដោយសារតែការខ្វះភាពស៊ីគ្នា និងភាពឯកភាពគ្នាក្នុងការអនុវត្តទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួមក្នុងប្រព័ន្ធច្បាប់ធំៗ"។

[៧០] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadić* កថាខណ្ឌ ២២៥ ។

ជនជាប់ចោទ ចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តដោយបុគ្គលផ្សេងទៀត ដែលប្រព្រឹត្តរួមគ្នា ប៉ុន្តែហួសពីអ្វីដែលជនជាប់ ចោទប៉ុនប៉ងធ្វើ [៧១] ។ ចំណុចនេះត្រូវបានគូសបញ្ជាក់រួចហើយ ក្នុងការសិក្សា Max-Planck ដែលធ្វើឡើងដោយការិយាល័យអយ្យការអមតុលាការ ICTY ("OTP") ដើម្បីឆ្លើយតបទៅនឹងចំណោទដែលចោទឡើងថា តើស្ថិតក្រោមកាលៈទេសៈអ្វី ដែលគេអាចដាក់ទណ្ឌកម្ម មេដឹកនាំដែលធ្វើប្រតិបត្តិការ"នៅខាងក្រោយឆាក" និងមិនបាន ប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់ខ្លួន[៧២]។ ការសិក្សា Max-Planck ដែល OTP មិនយកចិត្តដាក់ ជាប់រហូតមកនោះ បង្ហាញច្បាស់ថាទម្រង់មួយនៃការទទួលខុសត្រូវដែលពិភពលោកប្រើយ៉ាង លើសលុបនោះ គឺសហចារី ពុំមែនសហឧក្រិដ្ឋកម្មរួម ដូចដែលបានបង្កើតក្នុងករណី *Tadić* នោះទេ[៧៣]។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ពុំមែនជាគោលការណ៍សាកល និងពុំត្រូវបាន ប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោក ទទួលស្គាល់ជាសត្យានុម័ត នៅក្នុងការអនុវត្តរបស់ខ្លួនទេ[៧៤]។ ការិយាល័យព្រះរាជអាជ្ញា អះអាងថា "មានមូលហេតុគ្រប់គ្រាន់" នាំឲ្យជឿបានថាទម្រង់ទីបី នៃសហឧក្រិដ្ឋកម្មរួម អាចត្រូវបានបង្កើតក្នុងច្បាប់អន្តរជាតិ ដោយចាត់ទុកឋានៈរបស់វាថាជា

---

[៧១] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៤ ។

[៧២] *សូមមើល* Max-Planck វិទ្យាស្ថានសម្រាប់ច្បាប់ព្រហ្មទណ្ឌបរទេស និងអន្តរជាតិ, ការចូលរួមប្រព្រឹត្តបទល្មើស ជាមួយ ភាគ ១៖ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃមេដឹកនាំរបស់ក្រុម និងបណ្តាញឧក្រិដ្ឋជន។ *សូមមើល ជាពិសេស* សេចក្តីផ្តើម និងផ្នែកនៃការរៀបចំគម្រោង និងភាគ ១៖ ការវិភាគប៉ែបប្រៀបធៀបអំពីប្រព័ន្ធច្បាប់។ *សូមមើល* បណ្តឹង ឧទ្ធរណ៍ ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៨ ផងដែរ។

[៧៣] *សូមមើល* សារណារបស់ Ambos លេខ ៤១ ដែលសាស្ត្រាចារ្យ Ambos រិះគន់សេចក្តីសម្រេចមិនទំនងរបស់ អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY ក្នុងករណី *Stakić* សម្រាប់ការអះអាងថា ការអនុវត្តសហចារីជំនួសសហឧក្រិដ្ឋ កម្មរួម គឺហួសពីដែនសមត្ថកិច្ច។

[៧៤] គោលការណ៍ទូទៅនៃច្បាប់ "ត្រូវតែបានរកឃើញជាសត្យានុម័តនៅក្នុងប្រព័ន្ធច្បាប់ជាតិនៃប្រព័ន្ធច្បាប់ធំៗរបស់ ពិភពលោក"។ M. CHERIF BASSIOUNI ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ២៨៨-៨៩ (Kluwer 1999)។ *សូមមើល* សារណារបស់ Ambos ផ្នែក I.3-I.4 ដែលមានពន្យល់ថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ពុំឃើញ មានក្នុងប្រព័ន្ធច្បាប់ជាតិនៃប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោកទេ។

គោលការណ៍ទូទៅមួយនៃច្បាប់[៧៥] ហើយថាក្នុងឆ្នាំ ១៩៧៥-៧៩ "យុត្តិសាស្ត្រជាតិជាច្រើនបានទទួលស្គាល់ទម្រង់នៃសហចារី ដែលស្រដៀងគ្នានឹងការ ទទួលខុសត្រូវទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនេះ"[៧៦]។ អង្គបុរេជំនុំជម្រះយល់ឃើញថាបទល្មើស ដែលការិយាល័យសហព្រះរាជអាជ្ញាបានយោងទាំងនោះ (ជាបទល្មើសមិនទាន់បានសម្រេចផល ជាជាងទម្រង់នៃការទទួលខុសត្រូវ) គឺ "ជួយបានតិចតួចណាស់ដល់ការសម្រេចលើបញ្ហានៅចំពោះមុខនេះ[៧៧]"។ ឧទាហរណ៍ដែលការិយាល័យសហព្រះរាជអាជ្ញា បានលើកឡើងនោះ ក៏គ្មានបញ្ជាក់ពីអត្ថិភាពនៃទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាគោលការណ៍ទូទៅមួយនៃច្បាប់នោះដែរ។ អង្គបុរេជំនុំជម្រះទទួលស្គាល់រួចហើយថា ប្រព័ន្ធច្បាប់ផ្សេងៗគ្នា មានលក្ខណៈខុសគ្នាពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃធាតុអត្តនោម័តពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវទាំងនេះ[៧៨]។ សហមេធាវីការពារក្តី បញ្ចូលសារណាតាមផ្លូវតុលាការមុនៗរបស់ខ្លួន ដើម្បីធ្វើជាឯកសារយោងពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវដែលមានស្រាប់ និងមូលហេតុ ដែលទម្រង់ទាំងនោះមិនអាចមានលក្ខណៈស្មើទៅនឹងសហឧក្រិដ្ឋកម្មរួម[៧៩]។

២១. ការិយាល័យសហព្រះរាជអាជ្ញា ស្នើឱ្យ*អ្នកដែលពុំមែនជាភាគីក្នុងរឿងក្តី*ដាក់សារណាស្តីពីថាតើទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម អាចយកអនុវត្តបានថាជាគោលការណ៍ទូទៅមួយ

---

[៧៥] សំណើសុំ កថាខណ្ឌ ២៩ ។

[៧៦] ចូរចំណាំថា ការិយល័យសហព្រះរាជអាជ្ញា ផ្តល់ឧទាហរណ៍នៃការសមគំនិត និង*ក្រុមជនទុច្ចរិត* គឺជា បទល្មើសមិនទាន់បានសម្រេច ជាជាងទម្រង់នៃការទទួលខុសត្រូវ។ សូមមើលខាងលើ។

[៧៧] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម លេខ ២៥០ (បញ្ជាក់បន្ថែម) ។

[៧៨] *ដូចខាងលើ* កថាខណ្ឌ ៨៥។ *សូមមើល* សារណារបស់ McGill កថាខណ្ឌ ៤៨៖ "ប្រព័ន្ធព្រហ្មទណ្ឌជាតិជាច្រើន... បដិសេធ [ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម]។

[៧៩] *សូមមើល* បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៧-៤៨ និង ៦៣-៦៥។ ឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៩-២៤។ សារណាតបស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២០។

របស់ច្បាប់ដែរឬយ៉ាងណា ឬបើមិនដូច្នេះទេ ស្នើសុំដាក់សារណាបន្ថែមលើបញ្ហានេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង តម្កល់សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្ដីពីទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមទុកថាបានការនោះ[៨០]។ អង្គជំនុំជម្រះសាលាដំបូង គប្បីបដិសេធសំណើនេះ។ គ្មាន "មូលហេតុគ្រប់គ្រាន់" នាំឲ្យជឿបានថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមពិតជាទម្រង់ជាធរមានជាគោលការណ៍ទូទៅមួយនៃច្បាប់នោះទេ។ សំណើនេះ ត្រូវបានដាក់ដើម្បីពន្យឺតដំណើរក្ដី និងពុំមានយុត្តិកម្ម។

**ឃ. ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម មិនត្រូវបានព្យាករណ៍ជាមុន ឬអាចរកបានដោយលោក អៀង សារី**

**១. ភាពអាចព្យាការណ៍ជាមុន**

២២. អង្គបុរេជំនុំជម្រះ យល់ឃើញថា ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម មិនអាចត្រូវបានព្យាករណ៍ជាមុននោះទេ។ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ទោះបីខ្លួនយល់ឃើញថាទម្រង់ទីមួយ និងទី២នៃសហឧក្រិដ្ឋកម្មរួម មានមូលដ្ឋានក្នុងច្បាប់កម្ពុជាយ៉ាងណាក្ដី ក៏ខ្លួន៖

> មិនទាន់អាចកំណត់បាននៅឡើយទេនៅក្នុងច្បាប់កម្ពុជា ដែលអាចអនុវត្តបាននូវពេលវេលាដែលពាក់ព័ន្ធ នូវបទប្បញ្ញត្តិណាមួយដែលអាចផ្ដល់ជាការជូនដំណឹងដល់ជនត្រូវចោទថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ក៏អាចផ្ដន្ទាទោសបានផងដែរ[៨១]នោះ។

២៣. ទោះបីជាមានការយល់ឃើញយ៉ាងនេះក្ដី ក៏ការិយាល័យសហព្រះរាជអាជ្ញា លើកឡើងថាលក្ខខណ្ឌតម្រូវនៃភាពអាចព្យាករណ៍ជាមុន ត្រូវបានបំពេញរួចហើយ ដោយអះអាងថាអង្គបុរេជំនុំជម្រះភ័ន្តច្រឡំ ដ្បិតខ្លួនផ្អែកទៅលើច្បាប់ជាតិ ដើម្បីសម្រេចថាតើទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមត្រូវបានព្យាករណ៍ជាមុនដែរឬយ៉ាងណានោះ[៨២]។ ផ្ទុយពីអំណះអំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ មិនបានសម្រេចថា ទម្រង់ទីបីនៃ

---

[៨០] សំណើសុំ កថាខណ្ឌ ៣១ ។

[៨១] សាលដីការបស់ អ.ប.ជ លើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៧។

[៨២] សំណើ កថាខណ្ឌ ៣៥ ។

សហឧក្រិដ្ឋកម្មរួម មិនត្រូវបានគេព្យាករណ៍ជាមុននោះទេ ដោយឈរលើមូលដ្ឋាន*ត្រឹមតែ*ថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមពុំមានចែងក្នុងច្បាប់ជាតិទេប៉ុណ្ណោះទេ។ គេអាចយល់ឃើញនូវចំណុចនេះប្រសិនបើគេពិនិត្យឡើងវិញនូវការវិភាគរបស់អង្គបុរេជំនុំជម្រះស្តីពី ភាពអាចព្យាករណ៍ជាមុន នៃទម្រង់ទីមួយនិងទីពីរនៃសហឧក្រិដ្ឋកម្មរួម។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវទាំងនោះ ត្រូវព្យាករណ៍ជាមុនបាន ដោយសារតែ វាត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង មានមូលដ្ឋានក្នុងច្បាប់កម្ពុជា[៨៣]។ អង្គបុរេជំនុំជម្រះ សន្និដ្ឋានថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ពុំមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ពោលគឺអង្គជំនុំជម្រះ ពិចារណាលើភាពអាចព្យាករណ៍ជាមុននេះ ដោយឈរលើច្បាប់ជាតិ។ អង្គជំនុំជម្រះ យល់ឃើញថាទម្រង់ទីបីនៃសហឧក្រិដ្ឋរួមពុំមានមូលដ្ឋានក្នុងច្បាប់កម្ពុជាទេ ដូច្នេះ វាមិនអាចព្យាករណ៍ជាមុនបានទេ។ ការិយាល័យសហព្រះរាជអាជ្ញា អះអាងថា ប្រសិនបើ ត្រូវតែមានមូលដ្ឋានក្នុងច្បាប់ជាតិ សម្រាប់ទម្រង់នៃការទទួលខុសត្រូវ ដើម្បីអាចចាត់ទុកថាអាចព្យាករណ៍បានយ៉ាងណាក្តី ក៏ការបញ្ចូលការទទួលខុសត្រូវក្នុងការសមគំនិតក្នុង ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ អាច"ជាទូទៅ គាំទ្រគោលគំនិតជាមូលដ្ឋាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋរួមនេះ"[៨៤]។ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ការសមគំនិត ខុសគ្នាពីការទទួលខុសត្រូវនៃទម្រង់ទី៣នៃសហឧក្រិដ្ឋកម្មរួម។ វាពុំបានប្រាប់ជាមុនដល់ លោក អៀង សារី ថាគាត់អាចត្រូវគេដាក់ឲ្យទទួលខុសត្រូវក្រោមទម្រង់ទីបីនៃសហឧក្រិដ្ឋរួមនោះទេ[៨៥]។ ការិយាល័យសហព្រះរាជអាជ្ញា គ្មានលើកទឡ្ហីករណ៍ណាថ្មីពាក់ព័ន្ធនឹងភាពអាច

---

[៨៣] សេចក្តីរបស់អង្គបុរេជំនុំជម្រះស្តីពីសហឧក្រិដ្ឋរួម កថាខណ្ឌ ៧២។ *សូមមើលផងដែរ* Kiti Jayangakula, *តើទ្រឹស្តីសហឧក្រិដ្ឋកម្មរួមគឺជាទម្រង់ស្របច្បាប់សម្រាប់ការទទួលខុសត្រូវជាលក្ខណបុគ្គល? ការសិក្សាអំពីការជំនុំជម្រះក្តីខ្មែរក្រហម* (២០១០) សារណាថ្នាក់អនុបណ្ឌិត *ដែលអាចស្វែងរកបាននៅគេហទំព័រ* http://lup.lub.lu.se/luur/download?func=downloadFile&recordOId=1693741&fileOId=1693742.

[៨៤] សំណើសុំ កថាខណ្ឌ ៣៥ ។

[៨៥] *សូមមើល* សារណារបស់ Ambos ទំព័រ ២៩ ដល់ ៣០ ។

ព្យាករណ៍ជាមុននេះទេ[៨៦]។ សហមេធាវីការពារក្តី បញ្ចូលសារណាតាមផ្លូវតុលាការមុនៗរបស់ខ្លួន លើបញ្ហានេះ ដើម្បីជាឯកសារយោង[៨៧]។

**២. ភាពអាចរកបាន**

២៤. ការិយាល័យសហព្រះរាជអាជ្ញា អះអាងថាលក្ខខណ្ឌតម្រូវនៃភាពអាចរកបាននេះ បានបំពេញរួចហើយ។ **១)** ជម្រើសទូទៅរបស់“សាលក្តីអន្តរជាតិដទៃទៀត” សន្មតថាជាភាពអាចព្យាករណ៍ជាមុន និងភាពអាចរកបាន ប្រសិនបើការប្រព្រឹត្តអាចផ្តន្ទាទោសបានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលវេលាពាក់ព័ន្ធ និង **២)** ការអះអាងបញ្ជាក់ដែលចាំបាច់ដើម្បីសន្និដ្ឋានថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមជាទម្រង់មានសុពលភាពមួយនៃការទទួលខុសត្រូវ អាចរកបាននៅក្នុងពេលវេលាដែលពាក់ព័ន្ធ នោះ[៨៨]។ **ទីមួយ** ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម គ្មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ ដូច្នេះ គេមិនសន្មតថាអាចរកវាបាននោះទេ។ **ទីពីរ** ដូចពន្យល់ខាងលើ ករណីអន្តរជាតិមានតែពីរប៉ុណ្ណោះ ដែលប្រហែលអាចផ្តល់ការគាំទ្រដល់ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមក្នុងឆ្នាំ ១៩៧៥-៧៩។ ករណី ទាំងនេះខ្វះសេចក្តីសម្រេច ដែលមានសម្អាងហេតុមួយ ដើម្បីសន្និដ្ឋានថាការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានអនុវត្តពិតប្រាកដ។ វាប្រាកដជាមិនអាចទៅរួចទាល់តែសោះ ដែលថា លោក អៀង សារី អាចបានទទួលឯកសារមួយច្បាប់ស្តីពីករណីទាំងពីរនេះជាភាសាដែលគាត់អាចយល់បាន ជាពិសេសបើគិតទៅដល់កាលៈទេសៈនៅពេលនោះ។ ធម្មនុញ្ញ

---

[៨៦] ជាពិសេស ការិយាល័យសហព្រះរាជអាជ្ញា អះអាងថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ អាចត្រូវបានព្យាករណ៍ជាមុនដោយផ្អែកលើយុត្តិសាស្ត្រអន្តរជាតិ ការទទួលស្គាល់ដោយរដ្ឋជាក់លាក់មួយចំនួនអំពីទម្រង់នៃសហចារី ដែលមានទម្រង់ដូចគ្នាទៅនឹងទម្រង់ទីបី នៃសហឧក្រិដ្ឋរួម និង ចរិតលក្ខណៈនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ សំណើសុំ កថាខណ្ឌ ៣៣ និង ៣៦។

[៨៧] *សូមមើល* បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៤ ដល់ ៧៩។ សារណាតបស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣២ ដល់ ៣៨។ សេចក្តីសង្កេតបន្ថែម កថាខណ្ឌ ៥៥ ដល់ ៥៧។

[៨៨] សំណើសុំ កថាខណ្ឌ ៣៧។

សាលាក្ដីឃោធាអន្តរជាតិ និងសេចក្ដីសម្រេច ដែលសម្រេចដោយសាលាក្ដីនេះ ពុំគាំទ្រទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមទេ[៨៩]។ អត្ថិភាពរបស់វា មិនបានគូសបញ្ជាក់អំពីភាពអាចរកបាននោះទេ។

**ង. សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនមានសង្គតិភាពទៅនឹងកម្មវត្ថុនិងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិទេ**

២៥. ជាការត្រឹមត្រូវដែល អង្គបុរេជំនុំជម្រះ មិនបានពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[៩០] នៅពេលកំណត់ថាតើ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅអ.វ.ត.ក ដែរឬយ៉ាងណានោះ។ នេះមិនមែនជាបុរេលក្ខខណ្ឌ ដែលត្រូវតែបំពេញមុននឹងគេអាចអនុវត្តទម្រង់នៃការទទួលខុសត្រូវនោះទេ[៩១]។ វាពុំមែនជាការពិចារណាត្រឹមត្រូវនោះទេ[៩២]។ កសព មិនបានអះអាង ហើយក៏មិនបានបង្ហាញថាអង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំឡើយ។ បើទុកជាកម្មវត្ថុនិងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិត្រូវបាន

---

[៨៩] *សូមមើល* ខាងលើ កថាខណ្ឌ ១១ ។

[៩០] *សូមមើល* សំណើសុំ កថាខណ្ឌ ៣៨។

[៩១] ដូចអ្វីដែលអង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ ផ្អែកលើយុត្តិសាស្ត្ររបស់តុលាការ ICTY បុរេលក្ខខណ្ឌត្រូវមាន៖ ១) វាត្រូវមានចែងក្នុង[ច្បាប់ស្ដីពីការបង្កើត អវតក] ច្បាស់ ឬមិនច្បាស់ ២) វាត្រូវតែមានជាធរមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលសមស្រប ៣) ច្បាប់ដែលចែងថា ទម្រង់នៃការទទួលខុសត្រូវ ត្រូវតែអាចឲ្យអ្នកដែលបានប្រព្រឹត្តដូច្នេះរកបានយ៉ាងងាយនៅពេលសមស្រប និង ៤) ជននោះត្រូវតែអាចព្យាករណ៍ជាមុន ថាគាត់អាចនឹងត្រូវទទួលខុសត្រូវចំពោះអំពើរបស់គាត់ ប្រសិនបើចាប់ខ្លួន។ បណ្ដឹងឧទ្ធរណ៍ស្ដីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤០ ដល់ ៤១ ដោយដកស្រង់សេចក្ដីសម្រេចលើសហឧក្រិដ្ឋកម្មរួមក្នុងករណី *Ojdanić* កថាខណ្ឌ ២១។

[៩២] *សូមមើល ព្រះរាជអាជ្ញា ទល់នឹង Brđanin* IT-99-36-A សាលដីកា ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២00៧ កថាខណ្ឌ ៤២១ "អង្គជំនុំជម្រះតុលាការកំពូល ច្រានចោលទឡ្ហីករណ៍បែបទូរបាតុភូតសាស្ត្ររបស់ព្រះរាជអាជ្ញា ដែលថាសាលាក្ដីគប្បីអនុវត្តតាមទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួម ដោយសារតែ ទ្រឹស្ដីនេះអនុញ្ញាតឲ្យសាលាក្ដី "ចោទប្រកាន់ និងដាក់ទណ្ឌកម្មអ្នកដែលចូលរួមក្នុងបទឧក្រិដ្ឋអន្តរជាតិ ក្នុងឋានៈជាមេដឹកនាំ និងពុំមែនតែជាកូនចៅគេប៉ុណ្ណោះនោះទេ"។ ការពិចារណាលើគោលនយោបាយដូច្នេះ គឺមិនសមហេតុសមផលដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់ទ្រឹស្ដីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលទេ"។

ពិចារណាត្រឹមត្រូវក្តី ក៏វាមិនអាចនាំដល់ការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ អាចអនុវត្ត បានដែរ។

២៦. ការិយាល័យសហព្រះរាជអាជ្ញា អះអាងថា ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមស្របតាមកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ វា"ការពារសង្គម"[៩៣] និងជាយន្តការ "សមហេតុផល និងចាំបាច់" សម្រាប់ ការប្រព្រឹត្តបទឧក្រិដ្ឋដែលមានអង្គការចាត់តាំង និងបញ្ហាប្រឈមនៃការចោទប្រកាន់ចារីប្រភេទនេះ[៩៤]។ គោលបំណងនេះ ពុំអាចយកមកធ្វើជាមូលហេតុដើម្បីអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមបានទេ ដ្បិតវាខ្ទាស់គ្នានឹងគោលការណ៍ណែនាំជាមូលដ្ឋាន ដែលថាជនជាប់ចោទគួរត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះតែការប្រព្រឹត្តណាមួយ ដែលខ្លួនគាត់ម្នាក់ឯងត្រូវទទួលទោសប៉ុណ្ណោះ។ សហមេធាវីការពារក្តី បញ្ចូលសារណាតាមផ្លូវតុលាការមុនៗរបស់ខ្លួន ដើម្បីធ្វើជាឯកសារយោងលើបញ្ហានេះ[៩៥]។ លើសពីនេះទៅទៀត ដើម្បីជាប្រយោជន៍សម្រាប់ប្រព័ន្ធច្បាប់កម្ពុជា ក្នុងការអនុវត្តទស្សនាទានច្បាប់បរទេស នៅពេលមានគ្រប់គ្រាន់នូវទម្រង់នៃទទួលខុសត្រូវក្នុងច្បាប់ជាតិ ឬ ទម្រង់នៃការទទួលខុសត្រូវទាំងឡាយដែលមានឫសគល់នៅក្នុងច្បាប់ជាតិកម្ពុជា[៩៦]។

[៩៣] សំណើសុំ កថាខណ្ឌ ៣៨ ។

[៩៤] ដូចខាងលើ កថាខណ្ឌ ៣៩ ។

[៩៥] *សូមមើល* បណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៦១ ដល់ ៦២ និងលេខចុងទំព័រ ៨៩។ *សូមមើល* ឧបសម្ព័ន្ធ ៣ ស្តីពីបញ្ជីរាយនាមអ្នកប្រាជ្ញដែលបានរិះគន់សហឧក្រិដ្ឋកម្មរួម ឬទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ផងដែរ។

[៩៦] សម្រាប់ជាកិច្ចពិភាក្សាមួយលើបញ្ហាទាំងឡាយ ដែលកើតឡើងពេលទម្រង់នៃការទទួលខុសត្រូវមួយ គ្មានក្នុងច្បាប់ជាតិ ត្រូវបានគេនាំចូលពីក្រៅ និងអនុវត្ត *សូមមើល* Mark A. Drumbl, *អំពើហិង្សាសមូហភាព និងទណ្ឌកម្មបុគ្គល៖ ចរិតលក្ខណៈនៃការប្រព្រឹត្តបទឧក្រិដ្ឋសាហាវយង់ឃ្នងទ្រង់ទ្រាយធំ, ៩៩* 99 Nw. U.L. Rev. 539 (2005)។ "ភាពកាត់ផ្តាច់គ្នា កើតមានឡើង នៅពេលការស្វែងរកការទទួលខុសត្រូវ កើតឡើងតាមរយៈ<u>ដំណើរការមួយ ដែលប្រាសចាកពី ឬប្លែកពីទម្លាប់ក្នុងស្រុក</u>"។ ដូចខាងលើ ត្រង់ចំណុច ៦០២ (មានគូសបន្ទាត់បញ្ជាក់បន្ថែម)។ *សូមមើល* Luke Marsh & Michael Ramsden ៖ *សហឧក្រិដ្ឋកម្មរួម៖ ការឆ្លើយតបរបស់កម្ពុជាទៅនឹង* Tadić, 11 INT'L CRIM. L. REV. 137, 154 (2011), ដែលអ្នកនិពន្ធវិភាគយ៉ាងល្អិតល្អន់លើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កត់សម្គាល់ថា៖

២៧. ការិយាល័យសហព្រះរាជអាជ្ញា ដកស្រង់ចេញពីសេចក្តីសម្រេចបន្ទាន់បង្ខំរបស់សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ (STL) ដែលបញ្ជាក់ថា សហឧក្រិដ្ឋកម្មរួម អាចពន្លាតដើម្បីគ្របដណ្តប់បទល្មើសដទៃទៀត ដែលគេមិនបានយល់ព្រមតាមពីដើមដំបូងនៃគម្រោង ដរាបណាភ័ស្តុតាងបង្ហាញថា សមាជិករបស់សហឧក្រិដ្ឋកម្មរួមនេះបានយល់ព្រមទៅនឹងការពន្លាតនេះ[97]។ ការដកស្រង់នេះ មិនគាំទ្រដល់ទឡ្ហីករណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា។ វាគ្រាន់តែគូសបញ្ជាក់ថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម អាចមិន"ចាំបាច់" ដូចអ្វីដែលការិយាល័យសហព្រះរាជអាជ្ញាប្រាប់ឲ្យអង្គជំនុំជម្រះជឿតាមនោះទេ[98]។ ការណ៍ដែលទម្រង់

---

វាបានបញ្ជាក់យ៉ាងច្បាស់ នៅពេលជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ១ និង លេខ ២ បានជម្ទាស់ការអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនៅ អវតក។ ជននេះគឺជាអ្នកដែលស្វះស្វែងរកកេរតំណែលពិតប្រាកដ នៅក្នុងដំណើរស្វែងរកយុត្តិធម៌ដែលត្រូវបានពន្យារពេល តាមរយៈសាលាក្តីមួយដែលមានគោលបំណងជាក់ច្បាស់ ដើម្បីធ្វើជាគំរូសម្រាប់តុលាការកម្ពុជា។ អវតក ត្រូវបានរៀបចំឡើងដើម្បីផ្តល់លទ្ធភាពឲ្យប្រទេសកម្ពុជា អាចដោះស្រាយបញ្ហានៃទុក្ខវេទនាដ៏មហាធំធេងដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងរបបព្រៃផ្សៃ ប៉ុល ពត។ ទោះជាយ៉ាងនេះក្តី ភាពព្រៃផ្សៃរបស់ខ្មែរក្រហម ពុំគប្បីយកមកធ្វើជាយុត្តិកម្ម សម្រាប់ការអនុវត្តទស្សនាទានបែបទូលំទូលាយខ្លាំងនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម អាចជួយសម្រួលការផ្តន្ទាទោសជនដែលបានចូលរួមក្នុងការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ទាំងនោះ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ វាបំផ្លាញចោលនូវសេចក្តីគោរពចំពោះយុត្តិធម៌អន្តរជាតិ ធ្វើឲ្យចុះខ្សោយសារៈសំខាន់នៃការការសម្រេចពីពិរុទ្ធភាពរបស់សាលាក្តី និងធ្វើឲ្យប៉ះពាល់ដល់កេរតំណែលប្រវត្តិសាស្ត្ររបស់សាលាក្តីនេះ។

[97] សំណើសុំ កថាខណ្ឌ ៣៩។

[98] "ពោល ចារីនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ អាចដាក់ឲ្យទទួលខុសត្រូវចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល តាមរយៈទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ប៉ុន្តែវាអាស្រ័យលើកាលៈទេសៈ និងភ័ស្តុតាងដែលមានការទទួលខុសត្រូវរបស់ពួកគេអាច ជាចុងក្រោយត្រូវទទួលទោសតាម សហឧក្រិដ្ឋកម្មរួមទម្រង់ទី១បាន។ ចំណុចខុសគ្នាដ៏ធំបំផុតរវាងទម្រង់ទីមួយ និងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ដែលមានលក្ខណៈសំខាន់ជាទ្រឹស្តីនោះ គឺអាចមិនមែនជាចំណុចស្នូលមែនទែននោះទេ។ STL-11-01/I សេចក្តីសម្រេចបន្ទាន់បង្ខំស្តីពីច្បាប់ដែលអាចអនុវត្តបាន៖ ភេរវកម្ម ការសមគំនិត មនុស្សឃាត ការប្រព្រឹត្តបទឧក្រិដ្ឋ បទចោទត្រួត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤៧។

ទីបីនៃ សហឧក្រិដ្ឋរួម ពុំមែនជា“ការចាំបាច់” រឹតតែបញ្ជាក់បន្ថែមទៀតដោយទឡ្ហីករណ៍ផ្ទាល់ខ្លួនរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលថាទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម “ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីសភាវៈនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ” និងថាលទ្ធភាពមាន “តិចតួច”ប៉ុណ្ណោះ ដែលថា បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ មិនស្ថិតនៅក្នុងប្រភេទនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១នោះ[៩៩]។

២៨. នៅទីបំផុត ការិយាល័យសហព្រះរាជអាជ្ញា អះអាងថាជាការត្រឹមត្រូវ ភាពខុសគ្នាណាមួយក្នុងពិរុទ្ធភាពត្រូវយកមកពិចារណានៅពេលកំណត់ទោស[១00]។ អំណះអំណាងបែបនេះ មិនបានគិតគូរដល់អត្ថិភាពនៃទម្រង់នៃការទទួលខុសត្រូវដទៃទៀត ដូចជា ជួយនិងជម្រុញ ដែលអាចពិពណ៌នាសមស្របអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ និងការគោរពដល់គោលការណ៍នីត្យានុកូលភាព[១0១] នោះទេ។ ម្យ៉ាងទៀត ការិយាល័យសហព្រះរាជអាជ្ញា មិនបានពិចារណាអំពីលទ្ធភាពមួយដែលថា នៅពេលដាក់ទណ្ឌកម្មជនជាប់ចោទណាម្នាក់ដោយសារតែគាត់ជាសមាជិកនៅក្នុងក្រុមណាមួយ វាពិតជាអាចមើលស្រាលដល់ទោសកំហុសគាត់ក្នុងស្ថានភាព

[៩៩] សំណើសុំ កថាខណ្ឌ ២ ។

[១00] ដូចខាងលើ កថាខណ្ឌ ៤0 ។

[១0១] “ជំនួសឲ្យការរចនាទស្សនាទានច្បាប់ ដើម្បីឲ្យស៊ីគ្នាទៅនឹងតថភាពជាក់ស្តែង ជាការប្រសើរគេគប្បីទទួលស្គាល់ថាទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម គឺពុំមែនជាឧបករណ៍ដែលសមស្របងាយៗ ដើម្បីដោះស្រាយបញ្ហាការិយាធិបតេយ្យរបស់រដ្ឋ និងអង្គការធំៗ ដែលប្រឡាក់ប្រឡូសក្នុងឧក្រិដ្ឋកម្មអន្តរជាតិនោះទេ”។ Harmen van der Wilt *សហឧក្រិដ្ឋកម្មរួម៖ លទ្ធភាព និងដែនកំណត់* 5 J. INT'L CRIM. JUST. 91, 93 (2007)។ សាស្ត្រាចារ្យ Weigend កត់សម្គាល់ថា “ការពិតបញ្ហាគឺនៅត្រង់ថាតើបំណងប្រាថ្នា(ដែលសមហេតុសមផលមួយ)ដើម្បីនាំ “ចារី” មកជំនុំជម្រះក្តី គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់កំណត់នរណាជា “ចារី” នោះ បានដែរឬអត់នោះឯង។ ឬគេអាចនិយាយបានថា ក្នុងការប្រឹងបង់សំណាញ់សហឧក្រិដ្ឋកម្មរួមដើម្បីឲ្យមុខសំណាញ់នេះលាតសន្ធឹងបែបធំទូលាយបែបនេះ អាចជួបការលំបាកក្នុងការពន្យល់អំពីហេតុផលដែល ថាឲ្យតែត្រីជាប់ក្នុងសំណាញ់ គឺសុទ្ធតែសមនឹងទទួលទណ្ឌកម្មពីទោសអន្តរជាតិ”។ Thomas Weigend *ចេតនា កំហុសរបស់ច្បាប់ និងការសហការប្រព្រឹត្តក្នុងសេចក្តីសម្រេចលើកករណី* Lubanga *ស្តីពីការបញ្ជាក់បទចោទ* 6 J. INT'L CRIM. JUST. 471, 477 (2008)។

មួយចំនួន[១០២] នោះទេ។ អង្គជំនុំជម្រះសាលាដំបូងគប្បីចងចាំនូវការព្រមានរំឭករបស់សាស្ត្រាចារ្យ Schabas ដែលថាការអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម បណ្ដាលឲ្យមាន"ការផ្ដន្ទាទោសបែបសម្រុះសម្រួល ដែលចៀសមិនផុតពីធ្វើឲ្យអាប់ឱនដល់អត្ថន័យអប់រំនៃសាលក្រមរបស់សាលាក្ដី និង ប៉ះពាល់ដល់កេរដំណែលប្រវត្តិសាស្ត្រ"[១០៣]។

## III. សេចក្ដីសន្និដ្ឋាន និង សំណើសុំការដោះស្រាយ

បញ្ហានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺពាក់ព័ន្ធនឹងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុងស្ដីពីអញ្ញត្រកម្ម។ នេះ ជាបញ្ហាច្បាប់សុទ្ធសាធ។ ការស្ដាប់អង្គហេតុមុននឹងសម្រេចអំពីច្បាប់អ្វីដែលអាចអនុវត្តបាន គឺជាការមិនសមរម្យ៖ ប្រការនេះនាំឲ្យមានទស្សនៈមួយថា អង្គជំនុំជម្រះសាលាដំបូង ច្បាស់ជាបានគិតទុកជាមុនរួចជាស្រេចនូវលទ្ធផលដែលខ្លួនចង់បាន។ ដូច្នេះ សេចក្ដីត្រូវការចាំបាច់ដែលត្រូវស្ដាប់អង្គហេតុជាមុនសិន ហើយស្វែងរកតើយុត្តិសាស្ត្រអ្វីមួយនោះ អាចមានប្រយោជន៍ (ផ្ទុយនឹងភាពអាចអនុវត្តបាន) ដើម្បីសម្រេចលទ្ធផលនោះ។ មួយវិញទៀត សារណារបស់អ្នកដែលមិនជាភាគីក្នុងរឿងក្ដី ឬរបស់ការិយាល័យសហព្រះរាជអាជ្ញាស្ដីពីបញ្ហា ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវនៃទម្រង់ទី៣នៃ សហឧក្រិដ្ឋកម្មរួមនេះពុំចាំបាច់ទេ។ អង្គបុរេជំនុំជម្រះបានដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ដោយសម្រេចថា ការទទួលខុសត្រូវនៃទម្រង់ទី៣នៃសហឧក្រិដ្ឋកម្មរួម មិនអាចអនុវត្តបាននៅ អ.វ.ត.ក ទេ។ ការិយាល័យសហព្រះរាជអាជ្ញា ធ្វើមិនអើពើចំពោះវិធាន ៨៩(១) និងពុំបានដាក់ការជំទាស់ទេ។ ឥឡូវនេះ ខ្លួនមិនអាចសុំដំណោះស្រាយ ការកំណត់បទចោទឡើងវិញ

---

[១០២] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Martić*, IT-95-11-A សាលដីកាលើបណ្ដឹងឧទ្ធរណ៍ សាលដីកាដាច់ដោយឡែករបស់ចៅក្រម Schomburg ស្ដីពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ Milan Martić ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២។

[១០៣] William A. Schabas *ធាតុផ្សំអត្តនោម័ត និងសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី* 37 NEW ENGLAND L. REV. 1015, 1033-34. (2002-2003)។

ទៅតាមអង្គហេតុ ដើម្បីជាវិធីគេចវេសពីវិធាន ឬ ជួសជុលភាពខ្វះការយកចិត្តទុកដាក់របស់ខ្លួនបាននោះទេ។ ខាងក្រោមនេះគឺជាការយល់ឃើញដែលពាក់ព័ន្ធនៃអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ក្នុងរឿងក្តី *Karemera* ៖

> រដ្ឋអាជ្ញាភ័ន្តច្រឡំ ដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង អាចមិនសម្រេចលើការជំទាស់របស់ភាគីប្តឹងឧទ្ធរណ៍នៅពេលនេះបាន។ អនុលោមតាមវិធាន ៧២(ក) រាល់ញត្តិទាំងអស់ដែលជំទាស់ទៅនឹងយុត្តាធិការត្រូវតែ"សម្រេច"ក្នុងរយៈពេល ៦០ ថ្ងៃ និងនៅមុនការចាប់ផ្តើមនៃសេចក្តីសន្និដ្ឋានបើក។ នៅទីនេះ ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សម្រេចថា ញត្តិរបស់ភាគីប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងយុត្តាធិការ។ ទោះបីជាញត្តិពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការ អាចលើកឡើងនូវបញ្ហាមិនមែនរឿងយុត្តាធិការនៅក្នុងនោះ ហើយអង្គជំនុំជម្រះសាលាដំបូងផ្អាកពិចារណាយ៉ាងណាក្តីជាធម្មានុរូបក្តី ក៏នេះមិនមែនជាបញ្ហាពាក់ព័ន្ធដែរ។ បញ្ហានោះគឺថា ភាគីប្តឹងឧទ្ធរណ៍ធ្វើអោយភ័ន្តច្រលំដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្អាកពិចារណាទៅលើបញ្ហាផ្លូវច្បាប់សុទ្ធសាធពាក់ព័ន្ធនឹងដែនកំណត់នៃយុត្តាធិការរបស់សាលាក្តីដើម្បីអនុវត្តទម្រង់នៃការទទួល[១០៤]។

អាស្រ័យហេតុនេះ យោងតាមមូលហេតុដូចដែលបានរៀបរាប់ពីខាងដើម អង្គជំនុំជម្រះសាលាដំបូងគួរ៖

ក. **ច្រានចោល** សំណើនេះដោយសារដាក់មិនទាន់ពេលវេលា ឬបើមិនដូច្នេះទេ

ខ. **ផ្តល់** សវនាការផ្ទាល់មាត់ និងជាធារណៈ និង

គ. **សម្រេចថា** ថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មិនអាចអនុវត្តបាននៅ អវតក។

---

[១០៤] *ព្រះរាជអាជ្ញា ទល់នឹង Karemera et al.*, ICTR-98-44-AR72.5, ICTR-98-44-AR72.6, សេចក្តីសម្រេចស្តីពីបណ្តឹងលើបញ្ហាយុត្តាធិការ៖ សហឧក្រិដ្ឋកម្មរួម ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ២២។

________________ _______________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្ដីរបស់លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **២២** ខែកក្កដា ឆ្នាំ **២០១១**